[illegible]



[illegible]

[illegible]

[illegible]

រលកលោកធម៌ ថ្ងៃសុក្រ ១៥កើត ខែពិសាខ ព.ស ២៥៥០



# រលកលោកធម៌

រៀបរៀងដោយ

ភិក្ខុវជិរប្បញ្ញោ **សាន សុជា**

សម្រាប់ជាធម្មទាន



## បុគ្គលឯក

"បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ តើបុគ្គលឯកនោះគឺនរណា ?

**គឺព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ"**

## មាតាបិតាមានឈ្មោះ៤យ៉ាង



ភិក្ខុវជិរប្បញ្ញោ **សាន សុជា** និងញោមប្រុសស្រី

១- ជា "ព្រះព្រហ្ម" របស់កូន

២- ជា "បុព្វទេវតា" របស់កូន

៣- ជា "បុព្វាចារ្យ" របស់កូន

៤- ជា "អាហុនេយ្យបុគ្គល" របស់កូន

# មាតិកាអត្ថបទ

**ឈ្មោះធម៌** **ទំព័រ**


*ពាក្យបំភ្លឺ* .................................... ក

**លោកធម្មសូត្រទី៥** ............... ១

*អដ្ឋកថាលោកធម្មសូត្រទី៥* .......... ៦

**លោកវិបត្តិសូត្រទី៦** ............. ៩

*អដ្ឋកថាលោកវិបត្តិសូត្រទី៦* ........ ២០

**បទគួរពិចារណាបន្ថែមទៀត** .... ២១

**I-លាភ** និង **អលាភ** ............. ២៥

*ចំណុចល្អនៃការបានលាភ* ............ ២៦

គុណវិបត្តិនៃការមានលាភ ............ ២៨
លាភតែងសម្លាប់បុគ្គលពាល ...... ៣១
ត្រូវចេះតស៊ូនឹងការអត់លាភ .......... ៣៣
**II-យស និង អយស** ........... ៤២
ត្រូវប្រើយសឲ្យបានជាប្រយោជន៍ .... ៤៦
អយសប្រសូតចេញពីយស .......... ៤៨
ពេលបាត់យសក៏ជាឱកាសល្អ ......... ៥៨
**III-សរសើរ និង និន្ទា** ........... ៦២
សរសើរនិងនិន្ទាជាធម៌បុរាណ ......... ៦៣
រឿងអតុលឧបាសក .................... ៦៤
របស់ផ្អែមមិនប្រាកដជាល្អ ............ ៧៩
របស់ល្វីងជូរចត់មិនប្រាកដជាអាក្រក់. ៨៤
អ្នកនិន្ទាបានត្រឹមតែកាកសំណល់ .. ៨៧
កុំទុកអ្នកនិន្ទាជាសត្រូវ ................. ៩០
មិនត្រូវឲ្យអ្នកនិន្ទាសម្រេចបំណង .. ៩៣
កុំធ្វើជាមនុស្សប៉េងប៉ោង ............... ៩៥
**IV-សុខ និង ទុក្ខ** .................. ១០០
សុខជាឈ្មោះនៃទុក្ខយ៉ាងស្រាល ... ១០១
តើទ្រព្យអាចនាំក្តីសុខមកឲ្យបានទេ? ១០៦
សុខពីរយ៉ាង ............................. ១០៩
ប្រៀបធៀបសេចក្តីសុខទាំងពីរ ..... ១១២

ទុក្ខនិងជីវិតជារបស់តែមួយ ........... ១១៧
លោកាមិសសុខ ........................... ១២៦
ហេតុអ្វីព្រះពុទ្ធតែងសម្តែងអំពីទុក្ខ? ១២៩
ត្រូវត្រៀមខ្លួនទុកជាមុន ................. ១៣៣
គោតមប្រវត្តិ (អត្ថបទកំណាព្យ) .... ១៣៩
ឈ្មោះមាតាបិតា ៤ យ៉ាង (កំណាព្យ) ១៥០
ព្រៃគោសិង្គសាលវ័នរុងរឿងដោយសារកិច្ចុណា?..១៥៣
អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ..១៦៧
សៀវភៅដែលធ្លាប់បានរៀបរៀង ..... ១៦៨
ប៉ុស្តិ៍វិទ្យុដែលកំពុងផ្សព្វផ្សាយព្រះធម៌ ១៦៩
ឈ្មោះអ្នកឧបត្ថម្ភបោះពុម្ព...........១៧០



# ពាក្យបំភ្លឺ

**រលកលោកធម៌** គឺជាឈ្មោះនៃសៀវភៅថ្មីមួយទៀត ដែលបានរៀបរៀងឡើងក្នុងកាលនៃខ្ញុំមានអាយុ ៣០ ឆ្នាំគត់ បន្ទាប់ពីសៀវភៅ **ព្រះធម្មបទ៣០គាថា** ។

ជីវិតសត្វលោក នៅក្នុងត្រៃភព គឺជាការហែលឆ្លងកាត់នូវមហាសាគរ គឺវដ្តសង្សារ ដែលរកកោះត្រើយមិនប្រាកដ ។ កាលបើធ្វើដំណើរឆ្លងកាត់មហាសមុទ្រយ៉ាងនេះ គឺតែងតែជួបនូវរលក ដែលបក់បោកមកប៉ះត្រូវ

ដោយគេចមិនផុត ទើបខ្ញុំដាក់ឈ្មោះសៀវភៅថ្មីនេះថា **រលកលោកធម៌** ដែលជាធម៌តែងបក់បោកមកលើសត្វលោកគ្រប់គ្នា ។

សូមពុទ្ធបរិស័ទ បានស្វែងយល់អំពីលោកធម៌ ហើយកសាងសន្តានចិត្តឲ្យបានរឹងមាំដូចជាភ្នំថ្មតាន់ ដែលមិនញាប់ញ័រដោយកម្លាំងនៃលោកធម៌ទាំងអស់ ។

មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីវត្ត ឃុំរលាប ស្រុកសំពៅមាស
ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា

ថ្ងៃសុក្រ ១៥ កើត ខែពិសាខ អដ្ឋស័ក ព.ស ២៥៥០

**ភិក្ខុវជិរប្បញ្ញោ សាន-សុជា**



# លោកធម្មសូត្រទី៥ [១]

ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំងឡាយ ៨ យ៉ាងនេះ តែងជាប់តាមនូវសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ នេះដែរ ។ លោកធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ? គឺ លាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះឯង តែងជាប់តាមសត្វលោក ទាំងសត្វលោក ក៏វិលទៅតាម នូវលោកធម៌ទាំង

---

១-អង្គុ- អដ្ឋក- បណ្ណាសក មេត្តាវគ្គ បិដកលេខ ៤៨ ទំព័រ ១៣ ។

៨ យ៉ាងនេះដែរ។

**លាភោ អលាភោ ច យសាយសោ ច**
**និន្ទា បសំសា ច សុខំ ទុក្ខញ្ច**

ធម៌ទាំងឡាយនេះ គឺ លាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១

**ឯតេ អនិច្ចា មនុជេសុ ធម្មា**
**អសស្សតា វិបរិណាមធម្មា**

ជាធម៌មិនទៀង ក្នុងមនុស្សជាតិទាំងឡាយ ជាធម៌មិនឋិតថេរ មាន



សេចក្ដីប្រែប្រួលជាធម្មតា

**ឯតេ ច ញត្វា សតិមា សុមេធោ**
**អវេក្ខតិ វិបរិណាមធម្មេ**

ចំណែកបុគ្គលអ្នកមានប្រាជ្ញា មានស្មារតី លុះដឹងនូវធម៌ទាំងនេះហើយ រមែងពិចារណា នូវធម៌ដែលមាន សេចក្ដីប្រែប្រួលជាធម្មតា

**ឥដ្ឋស្ស ធម្មា ន មថេន្តិ ចិត្តំ**
**អនិដ្ឋតោ នោ បដិឃាតមេតិ**

ឥដ្ឋារម្មណ៍ទាំងឡាយ រមែងមិនញាំញីនូវចិត្តរបស់បុគ្គលនោះបាន ទាំង

អនិដ្ឋារម្មណ៍ ក៏មិនអាចប៉ះទង្គិចបាន

**តស្សានុរោធា អថ វា វិរោធា**

**វិធូបិតា អត្ថគតា ន សន្តិ**

សេចក្តីត្រេកអរ ឬថា សេចក្តីថ្នាំង
ថ្នាក់ចិត្ត ក៏បុគ្គលនោះបានកម្ចាត់បង់
ហើយ ដល់នូវសេចក្តីវិនាស មិនមាន
តទៅទៀតឡើយ

**បទញ្ច ញត្វា វិរជំ អសោកំ**

**សម្មប្បជានាតិ ភវស្ស បារគូតិ ។**

បុគ្គលអ្នកដល់ នូវត្រើយនៃភព
រមែងដឹងច្បាស់ដោយប្រពៃ ព្រោះដឹង



ច្បាស់នូវបទ គឺព្រះនិព្វាន ដែលមិនមាន
ធូលីគឺកិលេស មិនមានសេចក្តីសោក ។

ចប់លោកធម្មសូត្រទី៥



## អដ្ឋកថាលោកធម្មសូត្រទី៥

បឋមលោកធម្មសូត្រទី៥ មានសេចក្តីវិនិច្ឆ័យដូចតទៅនេះ

ដែលឈ្មោះថាលោកធម៌ ព្រោះជាធម៌របស់លោកៗ បុគ្គលដែលឈ្មោះថាជាអ្នករួចចាកនូវលោកធម៌ទាំងនេះ មិនមានសោះឡើយ សូម្បីព្រះសម្មាសម្ពុទ្ធទាំងឡាយក៏នៅមានដែរ ព្រោះហេតុដូច្នោះ ទើបទ្រង់ត្រាស់ថា **លោកំ អនុបរិវត្តន្តិ** រមែងវិលទៅតាមនូវសត្វលោក ។ មានសេចក្តីថា រមែងជាប់ទៅតាមមិនឈប់ឈរ បានដល់ការមិនត្រឡប់



អំពីលោកៗ

បទថា **លោកោ ច អដ្ឋ លោកធម្មេ អនុបរិវត្តតិ** ទាំងសត្វលោកនេះ ក៏រមែងជាប់តាមនូវលោកធម៌ទាំង៨នេះ អធិប្បាយថា មិនត្រឡប់ចាកធម៌ទាំងនោះ ។

ក្នុងបទថា **លាភោ អលាភោ** គប្បីជ្រាបថា កាលបើលាភមកដល់ហើយ ការមិនមានលាភក៏មកដល់ដូចគ្នាដែរៗ សូម្បីនៅក្នុងលោកធម៌ដទៃទៀត ដូចជាការមានយសជាដើម ក៏មានសេចក្តីដូចគ្នានេះដែរៗ

បទថា **អវេក្ខតិ វិបរិណាមធម្មេ** បានដល់ការពិចារណាយ៉ាងនេះថា ធម៌ទាំងនេះ

មានសេចក្តីប្រែប្រួលទៅជាធម្មតា ។

បទថា **វិទ្ធំសិតា** បានសេចក្តីថា វិនាសហើយ គឺថាកម្ចាត់អស់ហើយ ។

បទថា **បទញ្ច ញត្វា** បានដល់ការដឹងនូវបទ គឺព្រះនិព្វាន ។

បទថា **សម្មប្បជានាតិ ភវស្ស បារគូ** បានសេចក្តីថា កាលបើដឹងនូវបទ គឺព្រះនិព្វានហើយ រមែងដឹងដោយប្រពៃដល់សេចក្តី ដែលខ្លួនបានដល់នូវត្រើយនោះហើយ ក្នុងសូត្រនេះ ទ្រង់ត្រាស់ទាំងវដ្តៈនិងវិវដ្តៈ ។

ចប់អដ្ឋកថាលោកធម្មសូត្រទី៥



## លោកវិបត្តិសូត្រទី៦[១]

ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំងឡាយ ៨ យ៉ាងនេះ តែងជាប់តាមនូវសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ នេះដែរ ។ លោកធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ? គឺ លាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះឯង តែងជាប់តាមសត្វលោក ទាំងសត្វលោកក៏វិលទៅតាម នូវលោកធម៌ទាំង ៨ យ៉ាង

---

១-អង្គុ- អដ្ឋក- បណ្ណាសក មេត្តាវគ្គ បិដកលេខ ៤៨ ទំព័រ ១៥ ។

នេះដែរ ។ ម្នាលភិក្ខុទាំងឡាយ លាភក្តី អលាភក្តី យសក្តី អយសក្តី និន្ទាក្តី បសំសាក្តី សុខក្តី ទុក្ខក្តី តែងកើតឡើងដល់បុថុជ្ជនអ្នកមិនចេះដឹង ម្នាលភិក្ខុទាំងឡាយ លាភក្តី អលាភក្តី យសក្តី អយសក្តី និន្ទាក្តី បសំសាក្តី សុខក្តី ទុក្ខក្តី តែងកើតឡើងដល់អរិយសាវក អ្នកចេះដឹងដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះក្នុងលោកធម៌ទាំងនោះ មានសេចក្តីប្លែកគ្នាដូចម្តេច មានអធិប្បាយដូចម្តេច មានហេតុផ្សេងគ្នាដូចម្តេច របស់អរិយ-សាវកអ្នកចេះដឹង នឹងបុថុជ្ជនអ្នកមិនចេះដឹង ?



(ភិក្ខុទាំងឡាយតបថា) បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ មានព្រះដ៏មានព្រះភាគជាមូល មានព្រះដ៏មានព្រះភាគជាអ្នកណែនាំផង មានព្រះដ៏មានព្រះភាគជាទីពឹងរបស់យើងទាំងឡាយស្រាប់ហើយ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនៃភាសិតនោះ ជាក់ច្បាស់ដល់ព្រះដ៏មានព្រះភាគ ដោយល្អស្រាប់ហើយ ភិក្ខុទាំងឡាយបានស្តាប់ (ធម៌) របស់ព្រះដ៏-មានព្រះភាគ នឹងចងចាំទុកបាន ។

ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយប្រុងស្តាប់ ធ្វើទុកក្នុងចិត្តដោយ

ប្រពៃពចុះ តថាគតនឹងសម្ដែង ។

ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ព្រះមានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ លាភតែងកើតឡើងដល់បុថុជ្ជនអ្នកមិនចេះមិនដឹង បុថុជ្ជននោះមិនពិចារណា មិនដឹងច្បាស់តាមពិតដូច្នេះថា លាភនេះកើតឡើងដល់អាត្មាអញហើយ លាភនោះឯងមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា អលាភរមែងកើតឡើង យស... អយស... និន្ទា... បសំសា... សុខ... ទុក្ខរមែង



កើតឡើង (ដល់បុថុជ្ជនអ្នកមិនចេះដឹង) បុថុជ្ជននោះមិនពិចារណា មិនដឹងច្បាស់តាមពិតដូច្នេះថា ទុក្ខនេះកើតឡើងដល់អាត្មាអញហើយ ទុក្ខនោះឯងមិនទៀង ជារបស់អត់ធន់បានដោយក្រ មានសេចក្ដីប្រែប្រួលជាធម្មតា។ លាភក្ដី រមែងគ្របសង្កត់ចិត្តរបស់បុថុជ្ជននោះ អលាភក្ដី... យសក្ដី... អយសក្ដី... និន្ទាក្ដី... បសំសាក្ដី... សុខក្ដី... ទុក្ខក្ដី រមែងគ្របសង្កត់ចិត្ត ។

បុថុជ្ជននោះ តែងត្រេកអរនឹងលាភដែលកើតឡើង តូចចិត្តព្រោះអលាភ ត្រេកអរ

នឹងយសដែលកើតឡើង តូចចិត្តព្រោះអយស
ត្រេកអរនឹងបសំសាដែលកើតឡើង តូចចិត្ត
ព្រោះនិន្ទា ត្រេកអរនឹងសុខដែលកើតឡើង
តូចចិត្តព្រោះទុក្ខ ។

បុថុជ្ជននោះ ប្រកបនូវសេចក្តីត្រេកអរ
នឹងសេចក្តីតូចចិត្តយ៉ាងនេះហើយ រមែងមិនរួច
ចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខ
ទោមនស្ស ឧបាយាសៈ តថាគតពោលថា មិន
រួចចាកវដ្តទុក្ខឡើយ ។

ម្នាលភិក្ខុទាំងឡាយ លាភកើតឡើង
ដល់អរិយសាវកអ្នកចេះដឹង អរិយសាវកនោះ



ពិចារណាដឹងច្បាស់តាមពិតដូច្នេះថា លាភនេះ
កើតឡើងដល់អាត្មាអញហើយ លាភនោះឯង
មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជា
ធម្មតា អលាភកើតឡើង យស... អយស...
និន្ទា... បសំសា... សុខ... ទុក្ខកើតឡើង
អរិយសាវកនោះ ពិចារណាដឹងច្បាស់តាមពិត
ដូច្នេះថា ទុក្ខកើតឡើងដល់អាត្មាអញហើយ
ទុក្ខនោះឯងក៏មិនទៀង អត់ធន់បានដោយក្រ
មានសេចក្តីប្រែប្រួលជាធម្មតា ។

អរិយសាវកដឹងច្បាស់តាមពិតថា នេះ
ជាទុក្ខ ទុក្ខនោះឯងក៏មិនទៀង អត់ធន់បាន

ដោយក្រ មានសេចក្ដីប្រែប្រួលជាធម្មតា លាភក្ដី មិនគ្របសង្កត់ចិត្តរបស់អរិយសាវកនោះ អលាភក្ដី... យសក្ដី... អយសក្ដី... និន្ទាក្ដី... បសំសាក្ដី... សុខក្ដី... ទុក្ខក្ដី ក៏មិនគ្របសង្កត់ចិត្តបាន ។

អរិយសាវកនោះ មិនត្រេកអរនឹងលាភដែលកើតឡើង មិនអាក់អន់ព្រោះអលាភ មិនត្រេកអរនឹងយសដែលកើតឡើង មិនអាក់អន់ព្រោះអយស មិនត្រេកអរនឹងបសំសាដែលកើតឡើង មិនអាក់អន់ព្រោះនិន្ទា មិនត្រេកអរនឹងសុខដែលកើតឡើង មិន



អាក់អន់ព្រោះសេចក្ដីទុក្ខ ។

អរិយសាវកនោះ លះបង់សេចក្ដីត្រេកអរ និងសេចក្ដីអាក់អន់យ៉ាងនេះហើយ រមែងរួចចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថា រួចស្រឡះចាកវដ្ដទុក្ខបាន ។

ម្នាលភិក្ខុទាំងឡាយ នេះឯងជាសេចក្ដីប្លែកគ្នា នេះជាអធិប្បាយ នេះជាហេតុផ្សេងៗគ្នា នៃអរិយសាវកអ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង ។

ធម៌ទាំងឡាយនេះ គឺ លាភ ១ អលាភ ១

យស ១ អយស ១ និន្ទា ១
បសំសា ១ សុខ ១ ទុក្ខ ១ ជាធម៌
មិនទៀង ក្នុងមនុស្សជាតិទាំងឡាយ
ជាធម៌មិនឋិតថេរ មានសេចក្តីប្រែប្រួល
ជាធម្មតា ចំណែកបុគ្គលអ្នកមានប្រាជ្ញា
មានស្មារតី លុះដឹងនូវធម៌ទាំងនេះហើយ
រមែងពិចារណាឃើញច្បាស់ នូវធម៌
ដែលមានសេចក្តីប្រែប្រួល ជាធម្មតា
ឥដ្ឋារម្មណ៍ រមែងមិនញាំញីចិត្តរបស់
បុគ្គលនោះបាន ទាំងអនិដ្ឋារម្មណ៍ ក៏មិន
អាចប៉ះទង្គិចបាន សេចក្តីត្រេកអរ ឬថា
សេចក្តីថ្នាំងថ្នាក់ ក៏បុគ្គលនោះបាន



កម្ចាត់បង់ហើយ ដល់នូវសេចក្តីវិនាស
មិនមានតទៅទៀតឡើយ បុគ្គលអ្នកដល់
នូវត្រើយនៃភព រមែងដឹងច្បាស់ដោយ
ប្រពៃ ព្រោះដឹងច្បាស់នូវបទ គឺ
ព្រះនិព្វាន ដែលមិនមានធូលីគឺកិលេស
មិនមានសេចក្តីសោក ។

ចប់លោកវិបត្តិសូត្រទី៦



## អដ្ឋកថាលោកវិបត្តិសូត្រទី៦

ទុតិយលោកធម្មសូត្រទី៦ មានសេចក្តីវិនិច្ឆ័យដូចតទៅនេះ

បទថា **កោ វិសេសោ** មានសេចក្តីថា តើអ្វីជាហេតុប្លែកពីគ្នា ?

បទថា **កោ អធិប្បាយសោ** មានសេចក្តីថា តើអ្វីជាការប្រកបដ៏ក្រៃលែង ។

បទថា **បរិយាទាយ** មានសេចក្តីថា ការប្រកាន់ គឺប្រកាន់ដោយជុំវិញ ។

សូម្បីក្នុងសូត្រនេះ ព្រះអង្គក៏ទ្រង់ត្រាស់ទាំងវដ្តៈនិងវិវដ្តៈ ។

ចប់អដ្ឋកថាលោកវិបត្តិសូត្រទី៦



## បទគួរពិចារណា

## អំពីលោកធម៌បន្ថែមទៀត

សេចក្តីអន្ទះអន្ទែង ភ័យតក់ស្លុត និងសេចក្តីកង្វល់ចិត្ត តែងកើតចេញមកអំពីការស្រមើស្រមៃនៃចិត្ត ដែលត្រូវបានជះឥទ្ធិពលដោយសង្គមបរិយាកាសនៅជុំវិញជីវិត និងដោយមានឫសគល់ គឺតណ្ហា និងឧបាទាន ។

សាច់រឿងរបស់ជីវិតនេះ មិនខុសអ្វីអំពីសាច់រឿងនៅក្នុងកុន ឬល្ខោនឡើយ ជួនក៏បានសេចក្តីសុខ ជួនក៏ដល់នូវសេចក្តីទុក្ខ គឺមានសេចក្តីប្រែប្រួលជានិច្ច ព្រោះជាសង្ខតធម៌ កើតឡើងដោយមានបច្ច័យដែលជាគ្រឿង

ទំនុកបម្រុងច្រើនយ៉ាង ។

សុភមង្គលនៃជីវិត ហាក់បីដូចជាកន្លងទៅឆាប់រហ័សពេកណាស់ តែសេចក្ដីទុក្ខដែលកើតឡើងអស់រយៈតែមួយថ្ងៃ ក៏ហាក់បីដូចជាយូរ ហើយលំបាកក្នុងការអត់ទ្រាំដោយក្រៃលែង ។

ការអប់រំទូន្មានចិត្ត តាមរយៈការស្ដាប់និងសិក្សាព្រះធម៌ក្នុងសំណាក់ព្រះពុទ្ធសាសនាមិនមែនជាការបួងសួងសុំសេចក្ដីសុខ អំពីវត្ថុ ឬ បុគ្គលណាម្នាក់នោះទេ ហើយក៏មិនមែនជាការបញ្ចៀសនូវបញ្ហា មិនឲ្យកើតឡើងនោះដែរ តែជាការសិក្សាឲ្យចេះយល់ព្រមចំពោះ



បញ្ហាគ្រប់យ៉ាងទាំងអស់ ដែលកើតឡើងនៅក្នុងជីវិត ឲ្យក្លាយជាមនុស្សចេះទទួលស្គាល់ការពិត ចេះប្រើធម្មជាតិនៅជុំវិញខ្លួន ទោះជាល្អក្ដី អាក្រក់ក្ដីឲ្យបានជាប្រយោជន៍គ្រប់ករណី និងឲ្យបានជាបទពិសោធន៍សម្រាប់ជីវិតលោកីយ៍នេះ ។

ចិត្តរបស់មនុស្ស អាចមានឥទ្ធិពលគ្របដណ្ដប់លើសរីរៈទាំងមូលបាន ។ ចិត្តមានអានុភាពយ៉ាងខ្លាំងក្លា កាលណាចិត្តមានសភាពអាក្រក់ វាក៏អាចសម្លាប់ជីវិតមួយបាន តែកាលបើចិត្តមានសភាពល្អ វាក៏អាចផ្ដល់អត្ថប្រយោជន៍យ៉ាងធំធេង ដល់ខ្លួនឯងផង

និងដល់ជនទាំងឡាយដទៃផង ហើយចិត្តល្អ
នោះឯង គឺជាបុណ្យកុសល នាំឲ្យជីវិតរស់នៅ
ប្រកបដោយសុខុមាលភាពល្អ និងមានតែ
សភាពល្ហែល្ហើយក្សេមក្សាន្ត ។

ការបានយល់ដឹងអំពីលោកធម៌ គឺជា
កត្តាសំខាន់ណាស់ ដើម្បីជាឧបការៈជំនួយ
ដល់ការហ្វឹកហាត់ផ្លូវចិត្ត ឲ្យមានសេចក្ដីសុខ
ស្ងប់ក្នុងជីវិត ត្បិតនៅក្នុងលោកសន្និវាសនេះ
មិនមាននរណា សូម្បីតែម្នាក់អាចគេចផុត
អំពីលោកធម៌ទាំងនេះបានឡើយ ។





## I- **លាភ** និង **អលាភ**

ធម្មតាអ្នកជំនួញ តែងស្ថិតនៅក្រោម
ស្ថានភាពពីរយ៉ាងគឺ ខាត និង ចំណេញ ។

ជាទូទៅ គេតែងសប្បាយរីករាយនៅ
ពេលដែលគេបានលាភ គឺការចំណេញ ឬជា
ការបាននូវទ្រព្យសម្បត្តិ ហើយទាស់ចិត្តទៅ
នឹងការបាត់បង់លាភ ។

នៅក្នុងពិភពលោក ដែលពោរពេញ
ទៅដោយការប្រកួតប្រជែង និងច្របូកច្របល់
នេះ មនុស្សលោកតែងត្រូវការនូវសេចក្ដីសុខ
ណាមួយ ដែលញាំងចិត្ត ឬហឫទ័យរបស់គេ
ឲ្យរីករាយ ។

ការបានទូវលាភ ឬទ្រព្យសម្បត្តិ គឺ កើតឡើងដោយសារបុណ្យ ដែលធ្លាប់សន្សំ ទុកក្នុងកាលអតីតៈ រួមជាមួយនឹងសេចក្តី ប្រឹងប្រែងនាពេលបច្ចុប្បន្ន ។

## ចំណុចល្អនៃការបានលាភ

កាលបើមានលាភ ឬទ្រព្យសម្បត្តិ យើងអាចធ្វើអ្វីៗ ដែលទាក់ទងទៅនឹងការ ចំណាយធនធានបានដោយស្រួល ដូចជា[១]

១. ចិញ្ចឹមជីវិតខ្លួនឯង មាតាបិតា បុត្រ ភរិយា ឬទាសកម្មករដែលនៅជាមួយខ្លួន។

១-អង្គុត្តរ- ចតុក្កនិ- បត្តកម្មវគ្គ បិដកលេខ៤២ ចាប់ពី ទំព័រ១៦៦ តទៅ។



២. ចាយទ្រព្យដើម្បីការពារទ្រព្យ គឺ ចាយដោយការវៃឆ្លាត ដើម្បីដោះខ្លួនឯង ឲ្យរួចពីសេចក្តីអន្តរាយផ្សេងៗ ដូចជាអន្តរាយ ព្រោះភ្លើងព្រោះទឹក ឬក៏អន្តរាយព្រោះចោរ ជាដើម។

៣: ចាត់ចែង សម្រាប់ជួយសង្គ្រោះ ញាតិ និងទុកសម្រាប់ទទួលភ្ញៀវ ដែលមកពី ចម្ងាយ........ (សំដៅដល់ពលី៥យ៉ាង មាន ញាតិពលីជាដើម)។

៤. ចាត់ចែងបរិច្ចាគធ្វើទាន ដល់ សមណព្រាហ្មណ៍ អ្នកមានសីលជាទីស្រឡាញ់ ។

លាភ ឬទ្រព្យសម្បត្តិ អាចប្រើប្រាស់

ឲ្យបានជាប្រយោជន៍ច្រើនយ៉ាងទៀត ដែលទាក់ទងទៅនឹងការចំណាយធនធាន ដូចជាការបង់ថ្លៃសាលាជាដើម ។

## គុណវិបត្តិនៃការមានលាភ

លាភសក្ការៈ ឬទ្រព្យសម្បត្តិ អាចនាំឲ្យបានសម្រេចប្រយោជន៍ ដូចដែលបានរៀបរាប់មកខាងលើក៏ពិតមែនហើយ តែក៏អាចសម្លាប់នូវម្ចាស់របស់វា ដែលល្ងង់ខ្លៅបានផងដែរ ព្រោះលាភឬទ្រព្យសម្បត្តិមិនអាចជួយឲ្យមនុស្ស អស់នូវការសៅហ្មងបានឡើយ បើបាត់បង់ស្មារតីហើយ មនុស្សយើងមុខជា



សៅហ្មងដោយសារតែលាភ ឬទ្រព្យសម្បត្តិដោយពិតប្រាកដ ។

មនុស្សជាច្រើន កាលនៅមិនទាន់សម្បូរលាភ ឬទ្រព្យសម្បត្តិ មិនទាន់ជាភ្លើតភ្លើនប៉ុន្មានទេ លុះតែបានលាភ ឬទ្រព្យសម្បត្តិកើតឡើង ក៏ស្រាប់តែបែកគំនិតទៅក្នុងរឿងផ្សេងៗ ដូចជា ស្រី ស្រា ល្បែង និងបាបមិត្តជាដើម ដោយគេយល់ថា ទាល់តែហ៊ុហាសប្បាយចាយវាយ ទើបជីវិតមានន័យ។

គំហើញដ៏ខោតល្ងង់ របស់សត្វទាំងឡាយ បានបង្កើតឲ្យគេនូវគំនិតថា របស់ផ្សេងៗ ដែលជាគ្រឿងបម្រើសេចក្តីសប្បាយ

របស់ខ្លួន ឬដែលខ្លួនយកមកប្រើដើម្បីបម្រើសេចក្ដីសប្បាយនោះ គឺជាគំនិតដែលត្រឹមត្រូវ តែគំនិតសច្ចធម៌វិញច្ចុះបញ្ចាំងឲ្យឃើញច្បាស់ថា សត្វលោកទេតើ ដែលយកខ្លួនឯងទៅបម្រើរបស់ទាំងនោះ ក្នុងក្របខ័ណ្ឌនៃការបម្រើតណ្ហារបស់ខ្លួនឯង។

មនុស្សជាច្រើនយល់ថា មានប្រាក់មានអ្វីៗទាំងអស់ ហើយដោះស្រាយបញ្ហាអ្វីក៏បាន ប៉ុន្ដែគេមិនបានដឹងទាល់តែសោះថាប្រាក់ខ្លួនវាផ្ទាល់ ក៏នាំនូវបញ្ហាមកជាមួយដែរ ដូច្នេះប្រសិនបើគេប្រើប្រាស់ ដោយប្រាសចាកសតិស្មារតីហើយ គេមុខជានឹងស្រវឹងតាំងពី



ពេលដែលមិនទាន់ត្រូវស្រាម៉្ទេះ ។

## លាភតែងសម្លាប់បុគ្គលពាល

ចំពោះអ្នកប្រាថ្នាចេញចាកទុក្ខ ដូចជាភិក្ខុសាមណេរជាដើម បើជាអ្នកជូន់ក្នុងលាភហើយ មិនអាចគេចផុតពីសេចក្ដីទុក្ខបានឡើយ គឺនាំមកតែការកង្វល់ និងការហួងហែងរហូតដល់មានការច្រណែនឈ្នានីស ព្រមទាំងអាចឈានចូលទៅដល់ ការឈ្លោះប្រកែកគ្នាថែមទៀតផង ។

លាភដែលកើតឡើងចំពោះ ភិក្ខុ ឬសាមណេរដែលជាអ្នកជូន់ក្នុងលាភនោះ គឺ

កើតឡើងដើម្បីសម្លាប់បុគ្គលនោះឯង ដូចជា ដើមចេកដែលចេញផ្លែ ដើម្បីសម្លាប់តែខ្លួនឯង ឬដូចឫស្សី ដែលចេញផ្លែដើម្បីសម្លាប់ខ្លួនឯង ពុំនោះសោត ដូចជាមេសេះអស្សតរ ដែលមានផ្ទៃដើម្បីសម្លាប់ខ្លួនរបស់វា ដូចដែល ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា

**ផលំ វេ កទលឹ ហន្តិ**(១)
**ផលំ វេឡុំ ផលំ នឡំ**
**សក្ការោ កាបុរិសំ ហន្តិ**
**គព្ភោ អស្សតរឹ យថា ។**

ផ្លែចេកតែងសម្លាប់ដើមចេក ផ្លែឫស្សី

---

១-វិន័យបិដកលេខ ១១ សង្ឃភេទខន្ធកៈ ទំព័រ ២៥ ។



តែងសម្លាប់ដើមឫស្សី ផ្លែបបុសតែងសម្លាប់ ដើមបបុស សក្ការៈតែងសម្លាប់បុរសអាក្រក់ ដូចជាគភ៌តែងសម្លាប់មេសេះអស្សតរ ។

## ត្រូវចេះតស៊ូនឹងការអត់លាភ

មនុស្សដែលអាចអត់ទ្រាំ ចំពោះការអត់លាភ ឬការដែលបាត់បង់លាភទៅវិញបាននោះ ក៏ត្រូវតែជាមនុស្សចេះដឹងក្នុងធម្មជាតិដែលនៅជុំវិញជីវិត ឃើញថាជីវិត គឺយ៉ាងហ្នឹងឯង ជួនមានលាភ ជួនក៏បាត់លាភ ជារឿងធម្មតា ។

ការដែលមនុស្សយើង ចេះតែកើតទុក្ខ

ទោមនស្ស ព្រោះការដែលបាត់បង់លាភទៅ
ព្រោះគេគិតថា បញ្ហានេះមិនមែនជារឿងធម្មតា
តែកាលបើបានយល់ច្បាស់ថា ការមានលាភ
និងការអត់លាភ គឺជាគូគ្នាហើយនោះ មិនមាន
រឿងអ្វីដែលត្រូវលំបាកចិត្តនោះឡើយ គឺអាច
ទទួលបានគ្រប់ករណី ។

កាលបើលាភកើតឡើង ក៏មិនត្រេក-
អរភ្លើតភ្លើន របូតបាត់បង់ស្មារតី ហើយត្រូវ
ចេះប្រើប្រាស់លាភនោះ ឲ្យបានជាប្រយោជន៍
ដល់ខ្លួនឯងនិងអ្នកដទៃ ហើយព្រមទាំងចេះ
ប្រើប្រាស់ ឲ្យសមជាម្ចាស់របស់លាភទាំងនោះ
មិនឲ្យលាភសក្ការៈ មានអំណាចលើឧត្តមគតិ



របស់ខ្លួនឡើយ ហើយត្រូវដឹងថាលាភដែល
កើតឡើងនោះ វាមិនមែនចេះតែកើតឡើង
របូតដោយមិនដាច់ខ្សែនោះទេ វាគង់តែលែង
កើត ឬបាត់បង់ទៅវិញមិនខាន យើងត្រូវតែ
ត្រៀមខ្លួនទុកជាមុន ។

មនុស្សជាច្រើន ឃើញតែគុណតម្លៃ
នៃទ្រព្យសម្បត្តិ តែតិចគ្នាណាស់ដែលឃើញ
ទោសរបស់ទ្រព្យសម្បត្តិ ព្រោះតែគេសម្លឹង
ឃើញតែផ្នែកល្អរបស់ទ្រព្យយ៉ាងនេះឯង ទើប
ពេលដែលទ្រព្យវិនាសបាត់បង់ទៅ លទ្ធផល
ដែលគេទទួលបាន គឺទុក្ខតូចចិត្ត ។

ដើម្បីការពារនូវសេចក្តីទុក្ខតូចចិត្ត មិន

ឲ្យកើតឡើង នៅពេលដែលទ្រព្យវិនាសទៅ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងនឹងភិក្ខុទាំងឡាយ ដូច្នេះថា[១]

"ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាង រមែងមាន នៅក្នុងភោគៈទាំងឡាយ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ? គឺ ភោគៈជាសាធារណៈដល់ភ្លើង ១ ភោគៈជាសាធារណៈដល់ទឹក ១ ភោគៈជាសាធារណៈដល់ព្រះរាជា ១ ភោគៈជាសាធារណៈដល់ចោរ ១ ភោគៈជាសាធារណៈដល់អ្នកទទួលមត៌ក ដែលមិនជាទីស្រឡាញ់ ១ ................

---

១-អង្គុត្តរនិកាយ បញ្ចកនិបាត ទីឃចារិកវគ្គ ទំព័រ ២៥៩ ។



ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងរមែងមាននៅក្នុងទ្រព្យសម្បត្តិ ... គឺអាស្រ័យភោគៈហើយ ញ៉ាំងខ្លួនឲ្យសុខ ឲ្យឆ្អែត រក្សាខ្លួនឲ្យសុខសប្បាយ ១ ញ៉ាំងមាតានិងបិតាឲ្យសុខ ឲ្យឆ្អែត រក្សាមាតាបិតាឲ្យសុខសប្បាយ ១ ញ៉ាំងកូនប្រពន្ធ ខ្ញុំ និងបុរសជាកម្មករឲ្យសុខ ឲ្យឆ្អែត រក្សាកូនប្រពន្ធ ខ្ញុំ និងបុរសជាកម្មករឲ្យសុខសប្បាយ ១ ញ៉ាំងមិត្រនិងអាមាត្យឲ្យសុខ ឲ្យឆ្អែត រក្សាមិត្រអាមាត្យ បានសុខសប្បាយ ១

តម្កល់ទុកនូវទាន មានផលដ៏ខ្ពស់ក្នុង
សមណព្រាហ្មណ៍ ជាទានឲ្យនូវ
អារម្មណ៍ដ៏ប្រសើរល្អ មានផលជា
សុខ ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ ១ ។
ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥
យ៉ាងនេះ រមែងមានក្នុងកោគះ
ទាំងឡាយ" ។

កាលបានសម្លឹងឃើញ ទោសនិង
អានិសង្សយ៉ាងនេះហើយ យើងនឹងទៅជា
មនុស្សមានឧបេក្ខាក្នុងការបានលាភ និងការ
អត់លាភ ។

ការដែលមិនបានសិក្សា អំពីសភាព



ធម្មតានៃជីវិត ហើយភ្ញាក់ផ្អើលទៅក្នុងរឿង
បន់ស្រន់ អង្វរករអំពីវត្ថុស័ក្តិសិទ្ធិផ្សេងៗ
រមែងមិនរួចចាក អំពីសេចក្តីអន្តរាយឡើយ
ព្រោះសត្វលោកប្រព្រឹត្តទៅតាមកម្ម ដែលខ្លួន
ធ្លាប់បានធ្វើហើយ (កម្មុនា វត្តតី លោកោ) ។

មានតែការយល់ដឹង អំពីរឿងរបស់
ជីវិតប៉ុណ្ណោះ ទើបអាចតស៊ូនឹងការអត់លាភ
បាន ។

☞ នៅពេលបានជួបលាភ .
គួរបានជ្រាបថាមិនទៀង
ព្រោះលាភដូចទឹកភ្លៀង
ជួនក៏រាំងមិនប្រាកដ ។

☞ ជូនបានដូចចំណង់

ជូនក៏បង់ខ្លួនកំសត់

រៀនបាននិងរៀនអត់

សត្វប្រាកដជួបគ្រប់គ្នា ។

☞ បើលោកកើតឡើងពិត

ត្រូវមានចិត្តគិតជ្រះថ្លា

ធ្វើទានក្នុងសាសនា

ឬក៏ជាសង្គ្រោះញាតិ ។

☞ បើបានមិនលះបង់

ជួយស្រោចស្រង់ជនឯទៀត



បានទោះពិតចោលម្សៀត

ព្រោះខ្វះញាតិរស់អាស្រូវ ។

☞ គួរធ្វើបុណ្យឲ្យហើយ

ទាន់នៅឡើយទ្រព្យគង់នៅ

ពេលទ្រព្យវិនាសទៅ

ក្រែងអស់ផ្លូវខានធ្វើទាន ។



## II- យស និង អយស

ការមានយស និងការអត់យស ក៏ជាព្រឹត្តិការណ៍មួយ ដែលសត្វលោកគ្រប់គ្នាត្រូវតែប្រឈមមុខ ដោយមិនអាចជៀសផុត ។

**យស** តែងធ្វើហឫទ័យរបស់មនុស្សជាច្រើនឲ្យសប្បាយរីករាយភ្លើតភ្លើន និងទទួលបានដោយសេចក្តីសោមនស្ស ។

**អយស** គឺជាព្រឹត្តិការណ៍មួយ ដែលមនុស្សជាច្រើន ភ័យខ្លាច និងមិនចង់ឲ្យកើតឡើងជាដាច់ខាត តែគ្រប់គ្នាមិនអាចគេចវេសបានឡើយ ហើយបញ្ចប់ទៅដោយសេចក្តីទុក្ខ



និងតូចចិត្ត យ៉ាងគួរឲ្យអាណិត ។

សព្វថ្ងៃនេះ មានមនុស្សច្រើនណាស់ ដែលខ្វល់ខ្វាយនឹងការស្វែងរកកិត្តិយស អ្នកខ្លះចង់បានល្បី ក៏ចុះផ្សាយពីសកម្មភាព ឬថារូបភាពរបស់ខ្លួនតាមរយៈសារពត៌មាន ឬក៏តាមទស្សនាវដ្តីទៀតផង ។

អ្នកខ្លះក៏រៀបចំ ពិធីជប់លៀងណាមួយ ដើម្បីយកចិត្តអ្នកធំ ព្រោះប្រាថ្នាចង់បាននូវកិត្តិយសផ្ទាល់ខ្លួនរបស់គេ ។

អ្នកខ្លះរៀបចំធ្វើពិធីបុណ្យ យ៉ាងឱឡារិកគគ្រឹកគគ្រេង ធ្វើពិធីរាប់បាត្រព្រះសង្ឃរាប់ពាន់អង្គ ប៉ុន្តែគេអាចមិនយកចិត្តទុកដាក់

ទាល់តែសោះ ចំពោះជនទុគ៌ត ក្រខ្សត់ ស្រេកឃ្លាន នៅជុំវិញខ្លួនរបស់គេ គេអាចចោទប្រកាន់ ហើយផ្ដន្ទាទោសដល់មនុស្សស្រេកឃ្លានម្នាក់ ដែលបានលួចបេះផ្លែដូងមួយនៅក្នុងចំការរបស់គេ ប៉ុន្តែគេមិនស្ទាក់ស្ទើរនឹងឲ្យដូងមួយពាន់ផ្លែ ដើម្បីបានកេរ្តិ៍ឈ្មោះ ឬកិត្តិយសល្អនោះឡើយ ។

ទាំងនេះ គឺជាចំណុចខ្សោយរបស់មនុស្ស ហើយមនុស្សភាគច្រើន តែងតែមានគំនិតអាថ៌កំបាំង នៅពីខាងក្រោយសកម្មភាពរបស់ខ្លួន មិនងាយអ្នកណាម្នាក់ស្មានត្រូវឡើយ ដូចគេនិយាយថា ស្គាល់មុខ តែមិន



ងាយស្គាល់ចិត្ត ។

មនុស្សជាច្រើន ចូលចិត្តនិយាយអួតអាង ដើម្បីបាននូវកិត្តិយស ឬគុណ-សម្បត្តិ ប៉ុន្តែកិត្តិយស ឬគុណសម្បត្តិមិនមែនកើតឡើង ដោយការអួតអាងនោះទេ វានឹងកើតឡើងសមទៅនឹងសមត្ថភាព និងការប្រព្រឹត្តរបស់មនុស្សម្នាក់ៗ ។

ពេលដែលមានពន្លឺចាំងមក មនុស្សយើងតែងតែមានស្រមោល បើយើងខំប្រឹងដេញចាប់ស្រមោល ពិតជាចាប់មិនបានឡើយ តែបើយើងមិនតាមចាប់ទេ ស្រមោលនោះក៏មិនបានឃ្លាតទៅទីណាឆ្ងាយពីយើងដែរ គឺតែង

តែជាប់តាមទៅជានិច្ច ។ សូមកុំធ្វើជាមនុស្ស ដេញចាប់ស្រមោល ទុកឲ្យស្រមោលដើរតាមយើងវិញទៅចុះ ។

## ត្រូវប្រើយសឱ្យបានជាប្រយោជន៍

ជាការពិតណាស់ មនុស្សយើងតែងតែមានការរីករាយ នៅពេលដែលទទួលបាននូវកិត្តិយស ឬអំណាចបុណ្យសក្តិអ្វីមួយ ប៉ុន្តែគប្បីយល់ដឹងឲ្យបានច្បាស់ថា កិត្តិយស ឬក៏ឋានៈបុណ្យសក្តិ ដែលទទួលបានទាំងអស់នោះ គ្រាន់តែជាដំណាក់កាលឆ្លងកាត់មួយបែបតែប៉ុណ្ណោះ មិនមែនជាទិសដៅពិតប្រាកដ



នោះឡើយ ព្រោះជារបស់មិនទៀង គង់តែវិនាសទៅដោយពិតប្រាកដ គ្រាន់តែយូរឬឆាប់ប៉ុណ្ណោះ ។

ពេលទទួលបាននូវកិត្តិយស ឬអំណាចបុណ្យសក្តិ ត្រូវដឹងខ្លួនថា យើងជាមនុស្សមានសមត្ថភាព ក្នុងការធ្វើនូវប្រយោជន៍ណាមួយដល់សង្គម ព្រោះឱកាសបែបនេះមិនងាយកើតមាននោះទេ អាចនិយាយបានថាជាឱកាសមាស ឱកាសប្រាក់សម្រាប់មនុស្សម្នាក់ៗ បើពេលនេះ យើងមិនបានធ្វើនូវអំពើជាប្រយោជន៍ដល់មនុស្សច្រើនគ្នាទេ យើងពិតជាអស់ឱកាសមិនខានឡើយ ។

## អយសប្រសូតចេញពីយស

ការសាងអគារប្រណីតមួយ គេត្រូវចំណាយពេលវេលា និងការខិតខំប្រឹងប្រែងជាច្រើន ទើបបានសម្រេច ប៉ុន្តែអគារដ៏ប្រណីតនោះ អាចនឹងត្រូវគេបំផ្លាញឲ្យវិនាសទៅវិញ ក្នុងរយៈកាលមួយរំពេចតែប៉ុណ្ណោះ ឬថាបើគេមិនបំផ្លាញទេ វាគង់តែនឹងបាក់ទ្រុឌទ្រោមទៅដោយខ្លួនឯង ក្នុងគ្រាដែលដល់អាយុកាលរបស់វា ។

យ៉ាងណាមិញ កេរ្តិ៍ឈ្មោះ កិត្តិយស ឬក៏ឋានៈដែលទទួលបាន ក៏ត្រូវចំណាយការខិតខំប្រឹងប្រែងមិនតិចដែរ ហើយនឹងត្រូវដល់



នូវការអន្តរធានទៅវិញ ដោយការបៀតបៀនអំពីសំណាក់គូប្រកួតប្រជែង ឬថាបើគ្មានអ្នកបៀតបៀនទេ ក៏គង់វិនាសទៅដោយខ្លួនឯង ឬក៏ដោយការធ្វេសប្រហែសរបស់ម្ចាស់វា ។

ជាទូទៅ កេរ្តិ៍ឈ្មោះដ៏ល្បីល្បាញ គឺកើតឡើងអំពីការខិតខំប្រឹងប្រែង អស់កាលជាអង្វែង ទម្រាំតែត្រូវបានគេទទួលស្គាល់ថាជាមនុស្សអស្ចារ្យម្នាក់ ដូចជាព្រះសម្មាសម្ពុទ្ធត្រូវបានគេស្គាល់ថា

-ព្រះអរហំ ព្រោះព្រះអង្គទ្រង់បរិសុទ្ធិ

ឆ្ងាយចាកសឹកសត្រូវគឺកិលេស ដែលជាគ្រឿងសៅហ្មងគ្រប់ប្រការ ។

-សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

-វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ។

-សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺព្រះនិព្វាន ។



-លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវលោក គឺ សង្ខារលោក សត្វលោក និងឱកាសលោក ។

-អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាមួយប្រៀបស្មើបាន ។

-បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន ។

-សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គ

ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ។

-ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវអរិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង ។

-ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ទាក់ចោលហើយ គឺជាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

កេរ្តិ៍ឈ្មោះរបស់ព្រះអង្គទាំង ១០ នេះ មានសេចក្ដីពីរោះណាស់ ហើយសែនសក្ដិសមទៅនឹងការខំប្រឹងប្រែង របស់ព្រះអង្គដ៏ក្រៃលែង ។



ពុទ្ធបរិស័ទ តែងសូត្ររំលឹកដល់ឈ្មោះរបស់ព្រះអង្គជារៀងរាល់ថ្ងៃ ទាំងក្នុងអតីត ទាំងក្នុងបច្ចុប្បន្ន និងបន្តទៅក្នុងកាលអនាគតជាអង្វែងតទៅទៀត, ប៉ុន្តែ ចំពោះអ្នកដែលមិនជ្រះថ្លានឹងព្រះអង្គ ឬជាអ្នកដែលមានទិដ្ឋិផ្ទុយនឹងសច្ចធម៌វិញ ក៏មានការខិតខំប្រឹងប្រែងពោលមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់ព្រះអង្គមិនស្មើរដែរ ។

ដូចជាក្នុងកំលុងពេលដែល ព្រះអង្គនៅមានព្រះជន្មនៅឡើយ ពួកអ្នកបួសខាងក្រៅ

ព្រះពុទ្ធសាសនា ហើយមានប្រក្រតីប្រឆាំងនឹងព្រះសម្មាសម្ពុទ្ធ បានប្រើស្ត្រីម្នាក់ ឈ្មោះនាងសុន្ទរីឲ្យចូលទៅក្នុងវត្តពេលព្រលប់ និងឲ្យចេញមកវិញពេលភ្លឺស្រាងៗ ល្មមមើលគ្នាឃើញ ក្រោយមកពួកគេបានសម្លាប់នាងហើយប្រកាសដំណឹងមួលបង្កាច់ថា ព្រះសមណគោតម និងសាវកបានប្រព្រឹត្តអសទ្ធម្មលើនាងសុន្ទរី ហើយសម្លាប់នាងចោលដោយខ្លាចបែកការ ប៉ុន្តែការប៉ុនប៉ង របស់ពួកអ្នកប្រឆាំងទាំងអស់នោះ ត្រូវបានទទួលនូវការ



បរាជ័យទាំងស្រុង ។

ក្នុងរឿងនាងចិញ្ចា ក៏ស្រដៀងគ្នានេះដែរ ដោយនាងត្រូវបានអ្នកកាន់លទ្ធិសាសនាផ្សេងប្រើឲ្យចូលទៅកាន់វត្តជេតពន នៅពេលល្ងាច ហើយឲ្យចេញទៅវិញនៅពេលព្រលឹមអស់ពេលជាច្រើនខែក្រោយមក នាងធ្វើហាក់ដូចជាមានផ្ទៃពោះ ដោយយកឈើមកចងពទ្ធពោះរបស់ខ្លួន ។ ថ្ងៃមួយពេលដែលព្រះសាស្តាកំពុងប្រោសទេសនា នៅកណ្តាលពួកបរិស័ទ នាងក៏ទៅឈរនៅខាងមុខព្រះភក្ត្ររបស់

ព្រះអង្គដោយចោទប្រកាន់ថា ព្រះសាស្តាបាន ប្រព្រឹត្តអសទ្ធម្មជាមួយនឹងនាង រហូតធ្វើឲ្យ នាងមានផ្ទៃពោះ.......... ប៉ុន្តែអំពើរបស់នាង ចិញ្ចានោះ ក៏ត្រូវបានទទួលនូវការបរាជ័យ ។

ហេតុអ្វីក៏គេអាចហ៊ាន និយាយបង្កាច់ ព្រះអង្គ ?

មកពីគេមិនជ្រះថ្លានឹងព្រះអង្គ ម្យ៉ាង ទៀត មកពីព្រះអង្គមានភាពល្បីល្បាញខ្លាំង ហួសពីការស្មានរបស់គេ ហើយគេខ្លាចបាត់ លាភសក្ការៈ និងខ្លាចបាត់បង់កេរ្តិ៍ឈ្មោះ



ព្រោះតែភាពល្បីល្បាញរបស់ព្រះអង្គ ។

សូម្បីមហាបុរស ដូចជាព្រះសម្មាសម្ពុទ្ធជាដើម ក៏ត្រូវគេនិយាយបង្អាប់កេរ្តិ៍ ឈ្មោះទៅហើយ ចុះទម្រាំតែយើងគ្រប់គ្នា ?

ដូច្នេះ ពេលដែលកំពុងមានយស ឬ កេរ្តិ៍ឈ្មោះល្អ ឬក៏ឋានៈអ្វីមួយ មិនត្រូវភ្លើត ភ្លើនរហូតបាត់បង់ស្មារតីនោះទេ ត្រូវត្រៀមខ្លួន ចំពោះការវិនាសយសទៅវិញផង ព្រោះការ បាត់យស គឺប្រសូតចេញពីការមានយសនោះ ឯង ធ្វើដូច្នេះ យើងនឹងមិនតក់ស្លុតឡើយ ។

## ពេលបាត់យសក៏ជាឱកាសល្អ

ដើម្បីសម្រេចគោលដៅនៃជីវិត យើងត្រូវសិក្សាអំពីការបរាជ័យ និងជ័យជម្នះឲ្យបានច្បាស់លាស់ ។ អ្នកណាដែលមិនធ្លាប់ចាញ់ អ្នកនោះឯងក៏មិនធ្លាប់ឈ្នះដែរ ។

តាមពិត បរាជ័យ មិនត្រឹមតែជួយឲ្យយើងសម្រេចបាន នូវជ័យជម្នះប៉ុណ្ណោះទេ វាថែមទាំងជួយផ្តល់ នូវថាមពលឲ្យដល់យើង ធ្វើឲ្យយើងមានចិត្តរីករាយសោមនស្ស ហើយសប្បុរសដោយបទពិសោធន៍ទៀតផង ។

ជាការពិតហើយ ដែលមនុស្សយើងត្រូវតែមានកេរ្តិ៍ឈ្មោះល្អ ឬឋានៈជាអ្វីមួយ



នៅក្នុងសង្គម ប៉ុន្តែពេលដែលកេរ្តិ៍ឈ្មោះ ឬឋានៈយសសក្តិនោះបាត់បង់ទៅ ក៏ជាឱកាសល្អថ្មីមួយទៀត ដែលធ្វើឲ្យមនុស្សយើងបានយល់ដឹងនូវដំណើរជីវិតកាន់តែច្បាស់ និងសប្បុរសដោយបទពិសោធន៍ លុះដល់ពេលជាខាងក្រោយ នឹងក្លាយជាមនុស្សមានជ័យជម្នះ ដែលមិនងាយត្រឡប់ ទៅរកសភាពអន់ថយសារជាថ្មីម្តងទៀតនោះទេ ហើយនឹងក្លាយជាមនុស្សមានសតិ និងសម្បជញ្ញៈគ្រប់គ្រាន់ក្នុងកិច្ចបំពេញការងាររបស់ខ្លួន មិនប្រមាទធ្វេសប្រហែសក្នុងការងារ ដែលខ្លួនកំពុងធ្វើឡើយ ពីព្រោះចំណុចខ្សោយរបស់អ្នកខ្លាត

ឬអ្នកពូកែ គឺនៅត្រង់ដែលគេមើលងាយ ចំពោះការងារនោះឯង ។

នៅក្នុងដំណាក់កាល ដែលយើងបាត់បង់នូវកិត្តិយស ឬឋានន្តរស័ក្តិណាមួយនោះ ក៏ជាឱកាសល្អមួយបែបទៀត ដែលអនុញ្ញាតឲ្យយើង បានសន្សំនូវគុណធម៌ជាច្រើនដូចជា ធ្វើទាន សីល ស្តាប់ព្រះធម៌ ដើម្បីអប់រំផ្លូវចិត្ត ឬបម្រើមាតាបិតា ជាដើម ។

☞ កេរ្តិ៍ឈ្មោះយសថ្កើងថ្កាន
សត្វគ្រប់ប្រាណតែងប្រាថ្នា
ចង់ឲ្យគេគ្រប់គ្នា
ស្គាល់ខ្លួនថាអ្នកប្រសើរ ។



☞ ដល់ពេលបាត់បង់យស
ខូចកេរ្តិ៍ឈ្មោះអស់គ្រាន់បើ
លែងមានអ្នកអើពើ
ក៏រវើរវាយចិត្ត ។



## III-សរសើរ និង និន្ទា

ជាធម្មតា ក្នុងចំណោមបុគ្គលជាបុថុជ្ជនទាំងឡាយ តែងមានសេចក្ដីរីករាយទៅនឹងការបាននូវសេចក្ដីសរសើរ ហើយកើតសេចក្ដីទោមនស្ស តូចចិត្តទៅនឹងពាក្យរិះគន់ និន្ទាបន្ទាប បន្ថោក ស្ដីបន្ទោស ។

សេចក្ដីសរសើរ ប្រសិនបើសក្ដិសមទៅនឹងការប្រព្រឹត្ត ក៏រមែងពីរោះដល់ការស្ដាប់ តែបើមិនសក្ដិសម ឬថាមិនសមស្របទៅនឹងការប្រព្រឹត្តទេនោះ វាពិតជាក្លាយទៅជាការបញ្ឆោរ ឬបញ្ចើចបញ្ចើទៅវិញ បើទុកជាពីរោះក៏ដោយ សេចក្ដីសរសើរនោះ គឺមានលក្ខណៈ



ក្លែងបន្លំតែប៉ុណ្ណោះ ។

មនុស្សយើងដោយច្រើន គឺស្ថិតក្រោមការជះឥទ្ធិពល នៃពាក្យសរសើរ និងពាក្យនិន្ទាអំពីសំណាក់អ្នកដទៃ ប៉ុន្តែគប្បីយល់ឲ្យកាន់តែច្បាស់ថា ការសរសើរ និងការនិន្ទា គឺជាសម្លេង ដែលកើតចេញពីមាត់របស់អ្នកដទៃតែប៉ុណ្ណោះ វានឹងមិនមានឥទ្ធិពលអ្វីទាំងអស់ ប្រសិនបើវាមិនបានមកប៉ះត្រូវដល់ត្រចៀករបស់យើងទេនោះ ។

### សរសើរនិងនិន្ទាជាធម៌មានតាំងពីបុរាណ

ការសរសើរ និងការនិន្ទានេះ មិនមែន

ជារឿងចម្លែក ដែលទើបតែកើតមាននាពេលបច្ចុប្បន្ននេះទេ គឺកើតមានតាំងតែពីយូរយារណាស់មកហើយ ។

ទាក់ទងទៅនឹងការ សរសើរ និងការនិន្ទានេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងធម៌ប្រោសក្រុមអតុលឧបាសក ដែលមានដំណើររឿងដូចតទៅ ។

## រឿងអតុលឧបាសក

សម័យថ្ងៃមួយ អតុលឧបាសក បាននាំនូវឧបាសកប្រមាណ ៥០០ នាក់ផ្សេងទៀតចូលទៅកាន់សំណាក់ របស់ព្រះថេរៈមួយអង្គ



ព្រះនាមរេវតៈដើម្បីស្ដាប់ព្រះធម៌ ។

ប៉ុន្តែព្រះថេរៈអង្គនោះ ជាអ្នកមានកិរិយាចៀសចេញចាកអារម្មណ៍ ហើយចូលទៅក្នុងកម្មដ្ឋានដែលជាទីត្រេកអរ ជាអ្នកត្រាច់ទៅតែម្នាក់ឯង ដូចជាសត្វសីហៈ ព្រោះហេតុដូច្នោះ លោកមិនបានពោលពាក្យអ្វីមួយជាមួយនឹងពួកអតុលឧបាសកទាល់តែសោះ ។

អតុលឧបាសក ក៏មានចិត្តក្រោធខឹងជាខ្លាំង រួចក៏ធ្វើដំណើរទៅកាន់សំណាក់របស់ព្រះសារីបុត្រ ។

ព្រះសារីបុត្រសួរថា "តើអ្នកទាំងអស់គ្នាមកកាន់ទីនេះ ដើម្បីប្រយោជន៍អ្វីដែរ ?"

អតុលឧបាសកឆ្លើយថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាបាននាំនូវឧបាសកទាំងអស់នេះ ចូលទៅកាន់សំណាក់របស់ព្រះរេវតត្ថេរ ដើម្បីត្រូវការដល់កិរិយាស្តាប់នូវធម៌ ប៉ុន្តែលោកម្ចាស់អង្គនោះ មិនបាននិយាយស្តីនូវពាក្យអ្វីបន្តិចបន្តួច ជាមួយនឹងខ្ញុំព្រះករុណាទាល់តែសោះ ខ្ញុំព្រះករុណាក៏ក្រោធខឹងនឹងលោក រួចក៏បានធ្វើដំណើរមកកាន់សំណាក់ របស់លោកម្ចាស់នេះឯង បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់សម្តែងនូវធម៌ដល់ខ្ញុំព្រះករុណា ។

ព្រះសារីបុត្រមានថេរដីកាថា "ម្នាល



ឧបាសកទាំងឡាយ បើដូច្នោះអ្នកទាំងឡាយចូរអង្គុយចុះមក" រួចហើយលោកក៏សម្តែងអំពីព្រះអភិធម្ម យ៉ាងច្រើនសន្ធឹកសន្ធាប់ ។

អតុលឧបាសក ក៏ក្រោធខឹងដោយគិតថា "ធម៌ដែលឈ្មោះថា ព្រះអភិធម្ម គឺល្អិតពេកណាស់ សុខុមពេកណាស់ ព្រះថេរៈសម្តែងតែព្រះអភិធម្មយ៉ាងនេះ តើស្តាប់នូវព្រះអភិធម្មនេះ បានប្រយោជន៍អ្វីទៅ" រួចក៏នាំបរិវាររបស់ខ្លួន ចូលទៅសំណាក់របស់ព្រះអានន្ទត្ថេរ ។

ព្រះអានន្ទសួរថា "ម្នាលឧបាសក តើមានរឿងអ្វី ?"

អតុលឧបាសកពោលថា "បពិត្រលោកម្ចាស់ ពួកខ្ញុំព្រះករុណាទាំងឡាយបាននាំគ្នាចូលទៅរកព្រះរេវតត្ថេរ ដើម្បីស្តាប់នូវព្រះធម៌ ប៉ុន្តែគ្មានបានប្រយោជន៍អ្វីទាល់តែសោះ ដោយហោចទៅសូម្បីតែពាក្យសំណេះសំណាលបន្តិចបន្តួចក៏គ្មានដែរ ។ ខ្ញុំព្រះករុណាក៏មានចិត្តក្រោធខឹងជាខ្លាំង ហើយក៏ធ្វើដំណើរទៅកាន់សំណាក់ របស់ព្រះសារីបុត្រ ឯព្រះសារីបុត្រនោះទៀតសោត ក៏សម្តែងធម៌អភិធម្ម ដែលមានសេចក្តីដ៏ល្អិតក្រៃលែងដល់ខ្ញុំព្រះករុណាទាំងឡាយ ខ្ញុំព្រះករុណាទាំងឡាយ ក៏ក្រោធខឹងនឹងព្រះសារីបុត្រអង្គ



នោះទៀត ព្រោះតែលោកសម្តែងធម៌អភិធម្មជ្រៅពេក" ។

ព្រះអានន្ទមានថេរដីកាថា "បើដូច្នោះ អ្នកទាំងឡាយចូរអង្គុយចុះមក ហើយប្រុងប្រៀបស្តាប់ចុះ" រួចហើយលោកក៏សម្តែងនូវធម៌តែបន្តិចបន្តួចប៉ុណ្ណោះ ហើយជាធម៌ដែលគេអាចយល់ដឹងបានដោយងាយ ។

ពួកអតុលឧបាសកទាំងនោះ ក៏មានសេចក្តីក្រោធខឹងនឹងព្រះអានន្ទទៀត ព្រោះតែលោកសម្តែងធម៌បន្តិចបន្តួច និងមានសេចក្តីរាក់ពេក រួចក៏ធ្វើដំណើរទៅកាន់សំណាក់នៃព្រះសាស្តា ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា "ម្នាលឧបាសកទាំងឡាយ តើអ្នកទាំងឡាយធ្វើដំណើរមកកាន់ទីនេះ ព្រោះមានហេតុអ្វី ?"

ពួកអតុលឧបាសក បានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយធ្វើដំណើរមកកាន់ទីនេះ គឺប្រយោជន៍ដើម្បីស្តាប់នូវព្រះធម៌" ។

ព្រះសាស្តាត្រាស់សួរថា "ម្នាលឧបាសកទាំងឡាយ ចុះអ្នកទាំងឡាយបានស្តាប់ធម៌ខ្លះហើយឬ ?"



ពួកអតុលឧបាសក បានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលជាខាងដើម ខ្ញុំព្រះអង្គបានចូលទៅរកព្រះរេវតត្ថេរ តែលោកមិនបានពោលពាក្យអ្វី សូម្បីបន្តិចបន្តួច នឹងខ្ញុំព្រះអង្គទាំងឡាយទាល់តែសោះ ខ្ញុំព្រះអង្គក៏ក្រោធខឹង នឹងលោកម្ចាស់អង្គនោះ រួចចូលទៅរកព្រះសារីបុត្រ ហើយព្រះសារី-បុត្រនោះ ក៏សម្តែងធម៌ព្រះអភិធម្មច្រើនពេក និងជ្រៅពេក ខ្ញុំព្រះអង្គទាំងឡាយក៏មានការក្រោធខឹងនឹងលោក រួចធ្វើដំណើរចូលទៅរកព្រះអានន្ទត្ថេរ ឯព្រះអានន្ទត្ថេរនោះទៀតសោត

សម្ដែងធម៌ដល់ខ្ញុំព្រះអង្គទាំងឡាយ តិចពេក និងមានសេចក្ដីរាក់ពេក ខ្ញុំព្រះអង្គទាំងឡាយ មានសេចក្ដីក្រោធខឹង នឹងព្រះថេរៈអង្គនោះទៀត រួចក៏ធ្វើដំណើរមកកាន់សំណាក់របស់ព្រះអង្គនេះតែម្ដង" ។

ព្រះសាស្ដា កាលបើបានទ្រង់ព្រះសណ្ដាប់ នូវសំដីនៃអតុលឧបាសកដូច្នេះហើយ ក៏ទ្រង់ត្រាស់ថា "ម្នាលអតុលៈ កិរិយានិន្ទានិងកិរិយាសរសើរនុ៎ះ ពពួកជនទាំងឡាយធ្លាប់សន្សំមកហើយ ដោយច្រើនសន្ទឹកសន្ធាប់តាំងពីបុរាណកាលមកម្ល៉េះ ពួកជនទាំងឡាយ



តែងតិះដៀល នូវបុគ្គលជាអ្នកនៅស្ងៀមផង នូវបុគ្គលជាអ្នកមានសំដីច្រើនផង នូវបុគ្គលជាអ្នកមានសំដីតិចផង ត្បិតថា អ្នកដែលគេគប្បីតិះដៀលតែម្យ៉ាង ឬថា អ្នកដែលគេគប្បីសរសើរតែម្យ៉ាង មិនមានសោះឡើយ សូម្បីព្រះរាជាទាំងឡាយ អ្នកខ្លះក៏និន្ទា អ្នកខ្លះក៏សរសើរ, មហាប្រឹថពីក្ដី ព្រះចន្ទនិងព្រះអាទិត្យក្ដី ធាតុទាំងឡាយមានអាកាសជាដើមក្ដី ជនពួកខ្លះក៏និន្ទា ពួកខ្លះទៀតក៏សរសើរ, សូម្បីព្រះសម្មាសម្ពុទ្ធជាម្ចាស់ដែលគង់ប្រថាប់សម្ដែងព្រះធម៌ ក្នុងកណ្ដាលបរិស័ទ

ទាំង ៤ អ្នកខ្លះក៏និន្ទា អ្នកខ្លះក៏សរសើរ, ក៏ការនិន្ទានិងការសរសើរ នៃមនុស្សអន្ធពាលទាំងឡាយ មិនយកជាប្រមាណនោះទេ ប៉ុន្តែបុគ្គលដែលត្រូវបណ្ឌិតអ្នកមានប្រាជ្ញាតិះដៀល ទើបឈ្មោះថា ជាការតិះដៀល, បុគ្គលដែលត្រូវបណ្ឌិតអ្នកមានប្រាជ្ញា សរសើរហើយ ទើបឈ្មោះថា ជាការសរសើរ" ដូច្នេះហើយ បានត្រាស់សម្តែងនូវព្រះគាថានេះថា

**ពោរាណមេតំ អតុល**

**នេតំ អជ្ជតនាមិវ**



**និន្ទន្តិ តុណ្ហិមាសីនំ**

**និន្ទន្តិ ពហុភាណិនំ**

**មិតភាណិម្បិ និន្ទន្តិ**

**នត្ថិ លោកេ អនិន្ទិតោ ។**

ម្នាលអតុលៈ ការតិះដៀលនិងការសរសើរនេះ ជារបស់បូរាណ ការតិះដៀលនិងការសរសើរនេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ (ព្រោះថា) ជនទាំងឡាយ តែងនិន្ទាបុគ្គលទាំងឡាយអ្នកអង្គុយស្ងៀម ក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើន ក៏មាន និន្ទាអ្នក

និយាយល្មមប្រមាណ ក៏មាន (អ្នកណា ៗ ក៏ដោយ) ក្នុងលោក ដែលមិនត្រូវគេនិន្ទា គ្មានឡើយ ។

**ន ចាហុ ន ច ភវិស្សតិ**
**ន ចេតរហិ វិជ្ជតិ**
**ឯកន្តំ និន្ទិតោ បោសោ**
**ឯកន្តំ វា បសំសិតោ ។**

បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយតែក្នុងអតីតទេ នឹងមានទៅក្នុងអនាគតក៏ទេ



មានតែក្នុងបច្ចុប្បន្ននេះក៏ទេ ។

**យញ្ចេ វិញ្ញូ បសំសន្តិ**
**អនុវិច្ច សុវេ សុវេ**
**អច្ឆិទ្ទវុត្តឹ មេធាវឹ**
**បញ្ញាសីលសមាហិតំ**
**នេក្ខំ ជម្ពោនទស្សេវ**
**កោ តំ និន្ទិតុមរហតិ**
**ទេវាបិ នំ បសំសន្តិ**
**ព្រហ្មុនាបិ បសំសិតោ ។**

បើអ្នកប្រាជ្ញទាំងឡាយ សង្កេតមើល

ភល់ ៗ ថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ក្នុងបញ្ញានិងសីល អ្នកណាគួរនឹងនិន្ទាបុគ្គល ដែលដូចជាដ្ដោរនៃមាសជម្ពោនទនោះបាន សូម្បីទេវតានិងមនុស្សទាំងឡាយក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរ (ដូចគ្នា) ។

ក្នុងពេលចប់ព្រះធម៌ទេសនា ឧបាសកទាំង ៥០០ នោះ បានតាំងនៅក្នុងសោតា-បត្តិផលដោយប្រការដូច្នេះ ។



## របស់ផ្អែមមិនប្រាកដថាល្អ

គេសង្កេតឃើញថា ផ្លែឈើដែលមានរសជាតិផ្អែម កាលបើទុំជោរពេកអាចនឹងមានដង្កូវ ហើយបើពិសាច្រើនទៅ មុខជានឹងកើតជម្ងឺតម្កាត់ យ៉ាងណាមិញ ពាក្យសរសើរជាច្រើននៅក្នុងលោកនេះ ក៏អាចមានបង្កប់នូវគំនិតមិនស្អាតនៅក្នុងនោះផងដែរ ។

អ្នកខ្លះគេសរសើរយើង ក្នុងលក្ខណៈយកចិត្តយកថ្លើម ឬក្នុងលក្ខណៈវាយអែបស៊ីអប អ្នកខ្លះសរសើរក្នុងលក្ខណៈបញ្ចោរ

ដើម្បីផលប្រយោជន៍អ្វីមួយ ។

ពាក្យសរសើរខ្លះទៀត បើទុកជាគេសរសើរដោយគំនិតស្មោះត្រង់ក៏ដោយ ក៏មិនទាន់ប្រាកដថាត្រឹមត្រូវ ដែលគួរទទួលយកបាននោះដែរ ព្រោះភាគច្រើន គឺគេសរសើរទៅតាមការដែលគេពេញចិត្ត គេមិនសូវបានគិតពីរឿង ខុស ឬត្រូវ មានប្រយោជន៍ ឬខូចប្រយោជន៍នោះទេ ដូចជា

-បើយើងប៉ាវគេឲ្យផឹកស្រា អ្នកប្រមឹកនឹងសរសើរយើងថា យើងជាមនុស្សចិត្តល្អ ។



-បើយើងធ្វើជាអ្នកប្រដាល់ ពេលដែលយើងដាល់ឈ្នះ អ្នកដែលចូលចិត្តមើលកីឡាប្រដាល់ នឹងសរសើរយើងថា យើងខ្លាំងពូកែ ។

-បើយើងធ្វើជាអ្នកនេសាទ ហើយចាប់បានត្រីច្រើន អ្នកដែលចូលចិត្តក្នុងរឿងបាណាតិបាតនឹងសរសើរយើងថា យើងគឺជាមនុស្សឧស្សាហ៍ ហើយប៉ិនប្រសប់ខាងការធ្វើនេសាទ។

-បើយើងធ្វើជាចោរ ពេលដែលលួច

បានច្រើន បង្កំពិតជាសរសើរយើងថា យើងធ្វើការបានល្អ......... សរុបសេចក្តីគឺថា គេនឹងសរសើរក្នុងរឿងណា ដែលជាការពេញចិត្តរបស់គេ បើយើងជាមនុស្សស៊ីខ្សជោរ ហើយចង់បានតែពាក្យសរសើរ យើងនឹងក្លាយជាមនុស្សគ្មានលំនឹងខ្លួនឯងទាល់តែសោះ ដូចជាចក នឹងរសាត់ទៅគ្មានទិសដៅពិតប្រាកដ ។

ដែលនិយាយមកនេះ មិនមែនបានន័យថា យើងមិនត្រូវការពាក្យសរសើរនោះទេ ប៉ុន្តែត្រូវផ្ទៀងផ្ទាត់មើល ថាតើពាក្យដែលគេ



សរសើរយើងនោះ សមទៅនឹងការប្រព្រឹត្តរបស់យើងដែរឬទេ ហើយអំពើរបស់យើងដែលគេសរសើរនោះ ល្អ និងមានប្រយោជន៍ដែរឬទេ ប្រសិនបើត្រឹមត្រូវ ល្អ និងមានប្រយោជន៍ហើយនោះ វានឹងក្លាយទៅជាថ្នាំកម្លាំង ជួយឲ្យយើងកាន់តែល្អឡើង តែបើយើងធ្វើមិនល្អ ថែមទាំងជាអំពើបាបទៀតនោះ ហើយគេក៏សរសើរយើងដែរ ចូរកុំញ៉ាំងចិត្តឲ្យត្រេកអរឲ្យសោះ បើមិនដូច្នោះទេ ពាក្យសរសើរនោះនឹងក្លាយទៅជាថ្នាំពុល សម្រាប់

សម្លាប់យើងមិនខាន ។

## របស់ល្ងីងជូរចត់មិនប្រាកដថាអាក្រក់

របស់ល្ងីង ជូរ ឬចត់ បើគេចេះប្រើ នឹងបានជាប្រយោជន៍ដោយពិត ។ របស់ល្ងីង គេអាចប្រើធ្វើជាថ្នាំ បំបាត់គ្រុនក្តៅបាន, របស់ចត់ គេប្រើធ្វើជាថ្នាំក្រពះបាន, របស់ជូរ គេអាចប្រើប្រាស់បានច្រើនយ៉ាង ដូចជាស្ងោរស្ងួ គ្រឿងជាដើម យ៉ាងណាមិញ ពាក្យរិះគន់ និន្ទា បើយើងចេះប្រើ វានឹងក្លាយជាថ្នាំសម្រាប់



បំបាត់នូវភាពសៅហ្មងរបស់យើងបាន ។

ក្នុងភាពជាមនុស្ស ដែលកំពុងបំពេញកិច្ចការអ្វីមួយ ដើម្បីលើកស្ទួយខ្លួនឯងឲ្យរួចចាកផុតអំពីហីនភាព ជាការប្រពៃណាស់ដែលមានអ្នកជេទៃចារិះគន់និន្ទា ព្រោះអ្នកទាំងនោះហាក់ដូចជាកំពុងសាកល្បង នូវសមត្ថភាពរបស់យើង ធ្វើឲ្យយើងកាន់តែមានសេចក្តីប្រឹងប្រែង និងប្រុងប្រយ័ត្នទៀតឡើង ។

ការប្រកួតកីឡារត់ប្រណាំង គេពិតជាមិនអាចរកឃើញអ្នកជាប់ចំណាត់ថ្នាក់លេខ ១

បានទេ ប្រសិនបើមិនមានអ្នកទី ២ ទី ៣ ... ចូលមកប្រកួតទេនោះ ហើយការប្រកួតនោះទៀតសោត បើគូប្រកួតរបស់យើងជាអ្នកទន់ខ្សោយ ការឈ្នះរបស់យើងមិនសូវមានតម្លៃឡើយ តែបើយើងអាចឈ្នះក្នុងចំណោមអ្នកខ្លាំង ទើបជម្នះនោះមានតម្លៃដ៏ក្រៃលែង យ៉ាងណាមិញ នៅជុំវិញជីវិតរបស់យើង បើមិនមានអ្នកនិន្ទាឈ្នានីសដល់យើងទេ យើងក៏មិនបានដឹងថា កម្រិតចិត្តរបស់យើងមានការអត់ធន់បានប៉ុនណា បើអត់ធន់បានចំពោះ



ពាក្យនិន្ទាតិចតួច ចិត្តរបស់យើងក៏មិនទាន់មានសភាពគួរឲ្យកត់សម្គាល់អ្វីនោះដែរ តែបើអត់ធន់បានចំពោះពាក្យនិន្ទាខ្លាំងៗ នោះទើបជាលទ្ធផលល្អដែលគួរជាទីគាប់ចិត្ត ហើយអាចជាគតិឲ្យអ្នកជំនាន់ក្រោយ រលឹកឃើញហើយកើតសេចក្តីជ្រះថ្លាទៀតផង ដូចជាសេចក្តីអត់ធន់របស់ព្រះបរមពោធិសត្វជាដើម ។

## **អ្នកនិន្ទាបានត្រឹមតែភាគសំណល់**

កាលណា យើងឡើងភ្នំកាន់តែខ្ពស់

យើងកាន់តែលេចធ្លោ ហើយស្ថិតក្នុងក្រសែភ្នែកនៃមនុស្សទាំងឡាយដ៏ច្រើន ខ្នងរបស់យើងត្រូវបានគេឃើញយ៉ាងច្បាស់ តែផ្នែកខាងមុខរបស់យើងគេមិនអាចមើលឃើញទេ។

មនុស្សជាច្រើន នាំគ្នាស្វែងរកតែកំហុសខុសឆ្គង និងចាំលាតត្រដាងនូវទោសកំហុស ម្យ៉ាងទៀត គេច្រើនតែមានសេចក្តីសង្ស័យ ឬថាខ្វះទំនុកចិត្តទៅនឹងទង្វើរបស់យើង ហើយបំភ្លេចចោលនូវគុណសម្បត្តិដ៏លេចធ្លោដែលយើងបានធ្វើ ។ បុគ្គលដែល



មានសភាពយ៉ាងនេះ ប្រៀបបីដូចជាតម្រងសម្រាប់ច្រោះទឹកផ្លែឈើ ដែលបង្ហូរទឹកដ៏ផ្អែមឆ្ងាញ់ចេញអស់ បន្សល់ទុកតែកាកសំណល់ប៉ុណ្ណោះ បុគ្គលប្រភេទនេះមិនមែនជាមនុស្សគួរឲ្យយើងខឹងស្អប់ ឬតបតនោះទេ តាមពិតគឺជាមនុស្សដែលគួរឲ្យអាណិត ព្រោះគាត់ទទួលបានតែភាពសៅហ្មង អំពីយើងតែប៉ុណ្ណោះ គាត់មិនដែលទទួលបាន នូវរសជាតិដ៏ឈ្ងុយឆ្ងាញ់ គឺគុណសម្បត្តិរបស់យើងនោះទេ យើងមិនគួរបោះបង់ការងារល្អចោល ព្រោះតែ

ជនប្រកែទនេះឡើយ ដូចមានពាក្យដែលគេនិយាយថា "ហ្វូងឆ្កែចេះតែព្រុស ក្បួនរទេះចេះតែលឿនទៅមុខដោយស្ងប់ស្ងៀម" ។

## កុំទុកអ្នកនិន្ទាជាសត្រូវ

តាមពិត អ្នកតិះដៀល និន្ទាដល់យើង មិនមែនសុទ្ធតែ ជាសត្រូវរបស់យើងនោះទេ យើងអាចប្រើឱកាស នៃការរិះគន់របស់គេ ដើម្បីរកឲ្យឃើញ នូវចំណុចខ្សោយនៅក្នុងខ្លួន របស់យើង ដែលខ្លួនយើងផ្ទាល់មិនអាចមើល



ឃើញបាន ព្រោះយើងមិនអាចមើលខ្នងខ្លួនឯងឃើញឡើយ ដូច្នេះយើងអាចទុកអ្នកដទៃដែលចាំនិន្ទាយើង ដូចជាគ្រូឧបជ្ឈាយ៍ដែលចាំកែកំហុសឲ្យយើងទៅចុះ មិនគួរបោះបង់ចោលនូវការងារល្អ ឬការងារដែលជាបុណ្យកុសល ដោយសារតែពាក្យនិន្ទានោះទេ ។

ប្រសិនបើយើង អាចទទួលស្គាល់នូវចំណុចខ្សោយរបស់យើងបាន ហើយកែប្រែវាឲ្យបានត្រឹមត្រូវឡើងវិញ យើងមុខជានឹងបានទទួលនូវជ័យជម្នះគ្រប់ករណី នេះបើគេមានការ

តិះដៀលចំពោះកំហុស ដែលយើងមាន ពិតមែន តែបើគេតិះដៀលដោយប្រាសចាកការពិត ត្រូវស្វែងយល់ថា មកពីគេស្គាល់យើងមិនច្បាស់ ឬថាកម្រិតនៃការយល់ដឹងរបស់គេនៅទាបជាងយើង ទើបគេមិនអាចដឹងច្បាស់នូវអ្វីដែលយើងមាន ហើយក៏មិនចាំបាច់វែកញែកអ្វីដែរ ត្រូវតម្រង់ទិសដៅនៃការប្រព្រឹត្តរបស់យើងឲ្យកាន់តែល្អឡើង មិនត្រូវដកថយជាដាច់ខាត បើយើងយកពាក្យនិន្ទាខុសរបស់គេ មកធ្វើជាគ្រឿងរាំងស្ទះ



មិនយូរមិនឆាប់ យើងនឹងក្លាយជាមនុស្សចាញ់រហូត ហើយចាញ់ជាបឋម គឺចាញ់ខ្លួនឯង ព្រោះអស់សេចក្តីសុខស្ងប់ផ្លូវចិត្ត ។

## មិនត្រូវឱ្យអ្នកនិន្ទាសម្រេចបំណង

ប្រសិនបើកាលៈទេសៈ មិនតម្រូវឲ្យយើងស្រាយបំភ្លឺទេនោះ វាគ្មានប្រយោជន៍អ្វីទាល់តែសោះ ក្នុងការដែលយើងប្រើប្រាស់ពេលវេលា និងពាក្យសំដីទៅកែតម្រូវនូវការនិន្ទាខុសឆ្គងរបស់ពពួកជន ដែលគ្មាននូវ

វប្បធម៌ក្នុងខ្លួនទាំងនោះ ។

អ្នកនិន្ទាយើង គេនឹងរីករាយសប្បាយចិត្តណាស់ កាលណាគេឃើញយើងមានការឈឺចាប់, នោះហើយ គឺជាចំណុចតែមួយគត់ដែលគេរង់ចាំ ។

ប្រសិនបើយើងព្រងើយកន្តើយ ទៅនឹងការនិន្ទា តិះដៀល បន្តាច់បន្ថុចឈ្មោះនោះទៅវិញ ពាក្យនិយាយទាំងអស់នោះ មិនមានឥទ្ធិពលអ្វីឡើយ ហើយអ្នកនិយាយពិតជាខកបំណងមិនខាន និងបន្តឲ្យមានតែកាព



សៅហ្មងខ្លួនឯងតែប៉ុណ្ណោះ ប្រៀបដូចជាច្រែះដែលកើតអំពីដែកណា វារមែងស៊ីនូវដែកនោះវិញដោយពិតប្រាកដ ។

ចូរយកតម្រាប់តាមសត្វសីហៈ ព្រោះធម្មតារបស់សត្វសីហៈ មិនភ្ញាក់ផ្អើលដោយសូរគ្រហឹមរបស់សត្វទាំងឡាយផ្សេងឡើយ ។

## កុំធ្វើជាមនុស្សប៉េងប៉ោង

ធម្មតារបស់ប៉េងប៉ោង កាលបើគេមិនទាន់ផ្លុំឲ្យប៉ោង ក៏រមែងនៅស្ងិតជាប់បានយូរ

មិនងាយបែក ឬដាច់ខូចខាតឡើយ គឺនៅស្ងិត ល្អណាស់ តែកាលបើគេផ្លុំឲ្យប៉ោងឡើង ក៏ជាសញ្ញាថា គ្រោះថ្នាក់របស់វាជិតមកដល់ហើយ ប៉ោងតិច គ្រោះថ្នាក់ក៏តិច ប៉ោងខ្លាំង គ្រោះថ្នាក់ក៏កាន់តែខ្លាំង ព្រោះប៉ោងធំតែមាឌ ប៉ុន្តែស្បែករបស់វាកាន់តែស្តើង អាចនឹងបំបែកបានយ៉ាងងាយ ដោយហោចទៅសូម្បីតែស្លឹកស្មៅក៏អាចចាក់បំបែកបានដែរ ។

យ៉ាងណាមិញ ការសរសើរនិងការនិន្ទា គឺជាសម្លេងដែលកើតឡើងអំពីខ្យល់មាត់



របស់អ្នកដទៃតែប៉ុណ្ណោះ បើយើងធ្វើខ្លួនជាមនុស្សប៉េងប៉ោង យើងនឹងប៉ោងស្រកទៅតាមមាត់របស់គេ យើងមិនដែលពេញចិត្តទៅនឹងអំពើល្អដែលយើងបានធ្វើ ហើយថែមទាំងមិនដែលរវៀស ចំពោះអំពើអាក្រក់ដែលយើងបានប្រព្រឹត្តឡើយ ព្រោះយើងធ្វើអ្វីៗ ដើម្បីតែតម្រូវចិត្តរបស់អ្នកដទៃតែប៉ុណ្ណោះ ហើយសុំឬយកមកនូវពាក្យសរសើររាប់អាន និងបញ្ចៀសនូវពាក្យនិន្ទាបន្ទាប់បន្ថោន កាលបើយ៉ាងនេះ យើងនឹងក្លាយទៅជាមនុស្សអនាថា

ទាំងនៅក្នុងគំនរទ្រព្យសម្បត្តិ ឬទាំងនៅក្នុង

ប្រាសាទវិមានមិនខានឡើយ ព្រោះអ្នកដទៃ

មានច្រើនណាស់ យើងមិនអាចយកចិត្តគេ

បានគ្រប់គ្នាឡើយ ។

☞ សរសើរនិងរាប់អាន

ពិតរំខានសត្វមិនស្មើរ

ពោកសត្វឲ្យល្ងីល្ងើ

ភ្លើភ្លេចខ្លួនមិនដឹងប្រាណ ។



☞ បំពេញគ្រប់កិច្ចការ

ព្រោះប្រាថ្នាចង់ឲ្យបាន

មានគេឯងរាប់អាន

ប្រាណធ្លាក់ជ្រោះក៏មិនគិត ។



## IV-សុខ និង ទុក្ខ

សេចក្តីសុខ គឺជាវត្ថុបំណងដ៏សំខាន់ជាទីបំផុត ដែលសត្វលោកគ្រប់គ្នាប្រាថ្នាចង់បាន ប៉ុន្តែមិនមែនចេះតែបានឯងៗនោះទេ ព្រោះជារបស់កើតពីហេតុ បើហេតុនៃសេចក្តីសុខមិនមានហើយ ទោះជាប្រាថ្នា ឬអង្វរករយ៉ាងណាក៏មិនបានដែរ ។

សេចក្តីទុក្ខ គឺជារបស់ដែលសត្វលោកគ្រប់គ្នាភ័យខ្លាចជាទីបំផុត ហើយមិនប្រាថ្នា



ឲ្យជួបសោះឡើយ ប៉ុន្តែបើហេតុនៃសេចក្តីទុក្ខមានហើយ ទោះបីជាខិតខំបញ្ចៀសយ៉ាងណាក៏មិនអាចទប់ស្កាត់បានដែរ គឺត្រូវតែជួបដោយពិតប្រាកដ នេះជាច្បាប់ធម្មជាតិ ។

## សុខជាឈ្មោះនៃទុក្ខយ៉ាងស្រាល

សេចក្តីសុខ ដែលស្ថិតនៅក្នុងសេចក្តីស្រមៃនៃជនក្នុងលោកីយ៍នេះ ក៏គឺជាសេចក្តីទុក្ខដែលស្រាលស្តើងបន្តិចតែប៉ុណ្ណោះ គឺគេសំដៅទៅលើអ្វីដែលគេបានតាមប្រាថ្នា ឬថា

បើគេស្រឡាញ់នូវរបស់ណា គេក៏បាននូវរបស់នោះឯង ប៉ុន្តែគេមិនដឹងទាល់តែសោះថា របស់ជាទីប្រាថ្នា ឬរបស់ជាទីស្រឡាញ់នោះឯង គឺជាប្រភពនាំឲ្យមានបញ្ហាកង្វល់ផ្លូវចិត្ត ។

ការប្រាថ្នា ឬការស្រឡាញ់កាន់តែខ្លាំង លទ្ធផលចុងក្រោយ គឺសេចក្តីទុក្ខតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏កាន់តែខ្លាំងដែរ ព្រោះរបស់ជាទីស្រឡាញ់ក៏មិនទៀង ហើយចិត្តស្រឡាញ់នោះ ក៏មិនទៀង តែងប្រែប្រួលទៅជានិច្ច ។



នៅពេលវត្ថុជាទីប្រាថ្នា បានធ្លាក់ដល់ក្នុងដៃហើយ សេចក្តីប្រាថ្នាក្នុងវត្ថុផ្សេងទៀតក៏កើតមាន ទីបំផុតគេមិនអាចរកឃើញថា តើវត្ថុអ្វី ដែលជាទីពេញចិត្តពិតប្រាកដរបស់គេនោះឡើយ ។

តាមពិត សេចក្តីសុខទាំងអស់ ដែលកើតឡើងតាមរយៈទ្រព្យសម្បត្តិក្តី ឬថា តាមរយៈការសោយអារម្មណ៍ល្អៗ ដូចជាឃើញរូបល្អ ឮសម្លេងពីរោះ ធំក្លិនល្អ ដឹងរសល្អ ដឹងផោដ្ឋព្វៈល្អ ឬក៏ដឹងរឿងរ៉ាវល្អ ទាំងអស់

នេះ គ្រាន់តែជាសុខសញ្ញាប៉ុណ្ណោះ ជាលោកិយសុខ ជាសុខដែលកើតឡើងព្រោះការឲ្យនិយមន័យ ទៅលើអ្វីដែលជាទីរីករាយនៃចិត្តតែប៉ុណ្ណោះ តែបើពោលទៅដោយសភាវៈ សេចក្ដីរីករាយភ្លើតភ្លើនផ្លូវកាយ និងផ្លូវចិត្តទាំងអស់ក៏គឺជាទុក្ខសច្ចៈ ព្រោះនៅក្នុងលោកនេះ មានតែទុក្ខទេដែលកើតឡើង មានតែទុក្ខទេដែលតាំងនៅមានតែទុក្ខទេដែលរលត់ ក្រៅពីទុក្ខមិនមានអ្វីកើត ក្រៅពីទុក្ខមិនមានអ្វីតាំងនៅ ក្រៅពីទុក្ខមិនមានអ្វីរលត់ ។



ដូច្នេះ លោកិយសុខទាំងអស់ ក៏គឺជាឈ្មោះនៃសេចក្ដីទុក្ខនោះឯង គ្រាន់តែជាសេចក្ដីទុក្ខ ដែលស្រាលស្ដើងបន្តិចតែប៉ុណ្ណោះ ព្រោះសេចក្ដីសុខសោមនស្ស ទាំងអស់នោះមិនមែនជាទិសដៅពិតប្រាកដឡើយ គ្រាន់តែជាដំណាក់កាលឆ្លងកាត់ ឬថាជាសេចក្ដីសុខបណ្ដោះអាសន្នប៉ុណ្ណោះ ទីបំផុតនឹងត្រូវវិនាសប្រែប្រួលទៅ ដោយឥតមានសេសសល់អ្វីបន្តិចបន្តួចឡើយ ។

## តើទ្រព្យអាចនាំក្ដីសុខមកឱ្យបានទេ ?

គេតែងបានឮមនុស្សជាច្រើន នាំគ្នានិយាយថា មានទ្រព្យសម្បត្តិ ឬថាមានប្រាក់ មានអ្វីៗទាំងអស់ ។

ប្រសិនបើរបស់ទាំងអស់ អាចនាំមកនូវសេក្ដីសុខគ្រប់យ៉ាង ម៉េះសមពួកមហាសេដ្ឋី មហាមូលធនមិនមានសេចក្ដីខកចិត្តជាមួយនឹងជីវិតនោះទេ ។

គេសង្កេតឃើញថា ក្នុងប្រទេសណាដែលមានការរីកចម្រើនទៅដោយសម្ភារៈ ក្នុង



ប្រទេសនោះ មានមនុស្សកើតជំងឺសរសៃប្រសាទកាន់តែច្រើនឡើងដែរ ។

មិនចាំបាច់និយាយ ត្រឹមការបាននូវទ្រព្យសម្បត្តិ ឬកិត្តិយស កេរ្តិ៍ឈ្មោះ ឬការរាប់អានក្នុងសង្គមជម្មតា សូម្បីបាននូវផែនដីទាំងមូល បើមិនមានសេចក្ដីសន្ដោសទេ ពិតជាមិនអាចរកសេចក្ដីសុខ និងការគ្រប់គ្រាន់ឃើញបានឡើយ ។

ស្ដេចអាឡិចសង់ដ៏រ (Alexander) ដែលបាននាំទ័ពរាតត្បាត ដោយជោគជ័យដល់

ប្រទេសឥណ្ឌា ដណ្តើមកាន់កាប់ដែនដីទាំងឡាយ នៅតាមផ្លូវដែលកងទ័ពបានទៅដល់ ប៉ុន្តែទ្រង់បានដកដង្ហើមធំ ពីព្រោះមិនមានសេសសល់ ចំណែកដែនដីផ្សេងទៀតដើម្បីដណ្តើមកាន់កាប់ ។

តាមពិតទ្រព្យសម្បត្តិ ក៏មានគុណប្រយោជន៍របស់វាដែរ វាអាចជួយដោះស្រាយបញ្ហាខាងក្រៅៗ ដូចជាអាហារបរិភោគដើម្បីចម្អែតផ្ទៃជាដើម តែមិនអាចហាមសេចក្តីទុក្ខមិនឲ្យកើតឡើងបានឡើយ ។



## សុខពីរយ៉ាង

នៅក្នុងគម្ពីរ អង្គុត្តរនិកាយ ទុកនិបាត សុខវគ្គ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយនេះ មានពីរយ៉ាង ។ សេចក្តីសុខពីរយ៉ាង តើដូចម្តេច ? គឺសេចក្តីសុខប្រកបដោយអាមិសៈ (សាមិសសុខ) ១ សេចក្តីសុខមិនប្រកបដោយអាមិសៈ (និរាមិ-សសុខ) ១ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខ

ទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាល ភិក្ខុទាំងឡាយ បណ្តាសេចក្តីសុខទាំងពីរយ៉ាងនេះ និរាមិសសុខនុ៎ះប្រសើរជាង ។

សេចក្តីសុខដែលបរិបូណ៌ឈូឆរដោយកាមគុណទាំង ៥ ដែលទុកដូចជានុយជន្លឲ្យមនុស្សសត្វវង្វេងវង្វាន់ភ័ន្តច្រឡំ នាំឲ្យមានរាគៈ សេចក្តីត្រេកត្រអាល មានសេចក្តីប្រាថ្នាមិនចេះស្រាក ទាំងនេះហៅថា សាមិសសុខ ។

សេចក្តីសុខរបស់ព្រះអរិយៈ ឬរបស់កល្យាណបុថុជ្ជន ដែលស្រឡាញ់ពេញចិត្ត



ចំពោះការប្រព្រឹត្ត ក្នុងសាសនព្រហ្មចរិយធម៌ ឬពេញចិត្តចំពោះកាយវិវេក គឺការនៅស្ងប់ស្ងាត់ចាកកាមគុណ និងប្រកបដោយចិត្តវិវេក គឺការស្ងប់រម្ងាប់ដោយផ្លូវចិត្ត ដូចសេចក្តីសុខចិត្តរបស់បព្វជិត ដែលមិនអាស្រ័យគប់រកនូវកាមគុណ ទាំងនេះហៅថា និរាមិសសុខ ។

មយ៉ាងទៀត សេចក្តីសុខដែលមិនច្រឡូកច្រឡំដោយអារម្មណ៍ខាងក្រៅ បានដល់សេចក្តីសុខនៃព្រះអរិយៈទាំងឡាយ ដែលសម្រេចមគ្គ ផល និព្វាន នេះលោកហៅថា

"ទិភមិសសុខ" ដោយឧក្រិដ្ឋ ។

## ប្រៀបធៀបសេចក្ដីសុខទាំងពីរ

សេចក្ដីសុខ ដែលជាប់ទាក់ទងទៅនឹងកាមារម្មណ៍ផ្សេងៗ ជាសេចក្ដីសុខក្លែងបន្លំដោយអំណាចសញ្ញាវិបល្លាស គឺដោយការសម្គាល់ថា សុខក្នុងរបស់ដែលជាទុក្ខ ថាទៀងក្នុងរបស់ដែលមិនទៀង ថាស្អាតក្នុងរបស់ដែលមិនស្អាត ហើយសេចក្ដីសុខដែលជាប់ទាក់ទងនឹងកាមារម្មណ៍ទាំងអស់នោះ មិនដែល



បញ្ចប់ទៅដោយសេចក្ដីសុខស្ងប់ឡើយ គឺតែងបញ្ចប់ទៅដោយការសោកស្ដាយ ល្វីងជូរចត់ស្រណោះស្រណោកយ៉ាងកំសត់ ដូចជា

-ការត្រេកអរនឹងការជួបជុំ ចុងក្រោយនឹងកើតទុក្ខព្រោះការព្រាត់ប្រាសមិនខាន ។

-ការត្រេកអរ នឹងការមានបានទ្រព្យសម្បត្តិ ចុងក្រោយនឹងកើតទុក្ខព្រោះការវិនាសទ្រព្យមិនខាន ។

-ការត្រេកអរ នឹងការមានសុខភាពល្អ ចុងក្រោយនឹងកើតទុក្ខតូចចិត្ត ព្រោះការកើត

រោគាព្យាធិមិនមាន ។

-ការត្រេកអរ នឹងការដែលអ្នកដទៃគោរពរាប់អាន ចុងក្រោយនឹងកើតទុក្ខតូចចិត្ត ព្រោះគេលែងគោរពរាប់អាន .....ជាដើម ។

សរុបសេចក្ដីគឺថា សេចក្ដីសុខដែលជាលោកធម៌ទាំងអស់ តែងតែមានសភាពផ្អែមត្រជាក់ក្នុងកាលខាងដើម ហើយមានសភាពល្វីងជូរចត់ក្នុងកាលជាខាងក្រោយ ប្រៀបដូចជាការបរិភោគអំពៅ ពីខាងគល់ដេញទៅខាងចុងដូច្នោះឯង ។



ចំណែកនិរាមិសសុខ ជាសេចក្ដីសុខដែលមិនជាប់ទាក់ទង ទៅនឹងកាមារម្មណ៍ផ្សេងៗ សំដៅដល់ការត្រេកអរក្នុងធម៌ គឺជាសេចក្ដីត្រេកអរ ឈ្នះអស់សេចក្ដីត្រេកអរទាំងពួង ជាសេចក្ដីត្រេកអរដែលមិនវិលទៅរកភាពល្វីងជូរចត់ក្នុងជីវិតវិញទេ ព្រោះធម៌របស់សប្បុរស មិនចេះចាស់ ឈឺ ស្លាប់ឡើយ ជាសច្ចធម៌ កាលបើបុគ្គលមានការសេព ចម្រើនរឿយៗហើយ មានតែនាំសេចក្ដីក្សេមចិត្តមកប្រគល់ឲ្យអស់កាលជានិច្ច រហូត

ញុំាងបុគ្គលអ្នកប្រព្រឹត្តតាម ឲ្យបានដល់នូវត្រើយនៃសេចក្តីទុក្ខទាំងពួង ប្រៀបដូចជាការបរិភោគអំពៅពីខាងចុង ដេញទៅខាងគល់ដូច្នោះឯង គឺកាន់តែផ្អែមត្រជាក់រហូត ។

ព្រះភទ្ទិយៈ ជាស្តេចធំ ធ្លាប់មានសេចក្តីសុខដោយកាមគុណ ក្នុងកាលដែលលោកនៅជាព្រះរាជា គ្រប់គ្រងរាជសម្បត្តិ ក្រោយមកលោកបានមកបួស ក្នុងសំណាក់នៃព្រះមានព្រះភាគ ហើយក៏បានសម្រេចមគ្គផល ពេលដែលលោកគង់នៅតែម្នាក់ឯង លោក



បានបន្លឺឧទានវាចាថា "ឱ សុខអ្វីម្ល៉េះទេហ្ន៎ !" ដូច្នេះជារឿយៗ ............គឺលោកមានការកោតសរសើរនូវសេចក្តីសុខក្នុងនេក្ខម្មៈ ដែលប្រាសចាកការហួងហែងគ្រប់ប្រការ ។

## **ខន្ធនិងជីវិតជារបស់តែមួយ**

ការឃើញរូប ឮសម្លេង ធំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ដឹងរឿងរ៉ាវផ្សេងៗ និងការសោយអារម្មណ៍ជាសុខ ជាទុក្ខ ជាឧបេក្ខា ទាំងអស់គឺជាតួជីវិត ជារបស់ដែលប្រែប្រួល

មិនទៀងទាត់ តែងអស់ទៅ សូន្យទៅជាធម្មតា ហើយរបស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា គឺសូន្យចាកសត្វ បុគ្គលតួខ្លួន ព្រោះជារបស់ដែលកើតដោយអំណាចបច្ច័យច្រើនយ៉ាង មិនមែនស្ថិតក្រោមការបង្គាប់បញ្ជា របស់បុគ្គលណាម្នាក់ឡើយ ។

បើនិយាយទៅតាម សភាវធម្មជាតិដែលជាសច្ចធម៌ សព្វសត្វក្នុងសកលជាតុនេះ គឺស្ថិតនៅក្រោមអំណាច នៃសេចក្ដីទុក្ខស្រាប់



ស្រេចទៅហើយ ឯសេចក្ដីទុក្ខដែលមានជាប្រចាំនោះគឺ

-ជាតិទុក្ខ ជាតិគឺកិរិយាកើតឡើងនៃខន្ធ ជាហេតុនាំមកនូវទុក្ខ ។

-ជរាទុក្ខ ជរាគឺកិរិយាចាស់គ្រាំគ្រានៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ ។

-ព្យាធិទុក្ខ ព្យាធិគឺជំងឺដង្កាត់ទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ ។

-មរណទុក្ខ មរណៈគឺកិរិយាបែកធ្លាយនៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ ។

-សោកៈ គឺសេចក្តីសោយសោក សេចក្តីក្រៀមក្រំចិត្ត កើតឡើងព្រោះការវិនាសញាតិ ការវិនាសភោគទ្រព្យ ការវិនាសដោយរោគបៀតបៀន ការវិនាសសីល និងការវិនាសទិដ្ឋិ ក៏ជាហេតុនាំមកនូវទុក្ខ ។[1]

-បរិទេវៈ សេចក្តីខ្សឹកខ្សួល ទួញយំពោលរៀបរាប់ ត្អូញត្អែរ កើតឡើងព្រោះការវិនាសញាតិ ការវិនាសភោគទ្រព្យ ការវិនាសដោយរោគបៀតបៀន ការវិនាសសីល និងការវិនាសទិដ្ឋិ ក៏ជាហេតុនាំមកនូវទុក្ខ ។

---

១-សម្មោហវិនោទនី អដ្ឋកថាគម្ពីរវិភង្គ ។



-ទុក្ខៈ សេចក្តីមិនសប្បាយកាយ សេចក្តីទុក្ខកាយ សេចក្តីសោយអារម្មណ៍មិនសប្បាយ ដែលកើតអំពីកាយសម្ផស្ស ក៏ជាហេតុនាំមកនូវទុក្ខ ។

-ទោមនស្សៈ សេចក្តីមិនសប្បាយចិត្ត សេចក្តីទុក្ខចិត្ត សេចក្តីសោយអារម្មណ៍មិនសប្បាយ ដែលកើតអំពីចេតោសម្ផស្ស ក៏ជាហេតុនាំមកនូវទុក្ខ ។

-ឧបាយាសៈ សេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ កើតឡើងព្រោះការវិនាសញាតិ

ការវិនាសភោគទ្រព្យ ការវិនាសដោយរោគ
បៀតបៀន ការវិនាសសីល និងការវិនាស
ទិដ្ឋិ ក៏ជាហេតុនាំមកនូវទុក្ខ ។

-អប្បិយេហិ សម្បយោគទុក្ខ កិរិយា
ប្រកបដោយអារម្មណ៍ ដែលមិនជាទីប្រាថ្នា
មិនជាទីចូលចិត្ត មិនជាទីពេញចិត្តនៅក្នុង
លោក បានដល់ រូប សម្លេង ក្លិន រស
ផោដ្ឋព្វៈ ឬការប្រសព្វនឹងបុគ្គលដែលបង្ក
សេចក្តីវិនាស អ្នកទម្លាយនូវប្រយោជន៍
អ្នកបង្កសេចក្តីអន្តរាយ ក៏ជាហេតុនាំមក



នូវទុក្ខ ។

-បិយេហិ វិប្បយោគទុក្ខ កិរិយា
ព្រាត់ប្រាសចាកអារម្មណ៍ ជាទីប្រាថ្នាក្នុង
លោក បានដល់ រូប សម្លេង ក្លិន រស
ផោដ្ឋព្វៈ ឬព្រាត់ប្រាសចាកបុគ្គលដែលជាទី
ស្រឡាញ់ពេញចិត្ត បានដល់ មាតា បិតា
បងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី មិត្រ
អាមាត្យ ញាតិ សាលោហិត ក៏ជាហេតុ
នាំមកនូវទុក្ខ ។

-យម្បិច្ឆំ ន លភតិ តម្បិទុក្ខ កាលបង់

បាននូវវត្ថុណាមួយហើយ មិនបាននូវវត្ថុនោះ កិរិយាមិនបាននោះ ក៏ជាហេតុនាំមកនូវទុក្ខ ។

-សង្ខិត្តេន បញ្ចុបាទានក្ខន្ធទុក្ខា ឧបាទានក្ខន្ធទាំងឡាយ៥ ដែលព្រះតថាគតសម្តែងហើយដោយសង្ខេប គឺ រូបូបាទានក្ខន្ធ វេទនូបាទានក្ខន្ធ សញ្ញូបាទានក្ខន្ធ សង្ខារូបាទានក្ខន្ធ និងវិញ្ញាណូបាទានក្ខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ ។

កងទុក្ខទាំង ១២ នេះ គឺជាសច្ចធម៌មួយប្រភេទ ក្នុងបណ្តាអរិយសច្ចធម៌ទាំង ៤ ហើយមានប្រចាំលោកនេះជានិច្ច ។



ក្នុងបណ្តាសច្ចៈទាំង ៤ នោះ សច្ចធម៌ ៣ គឺ ទុក្ខសច្ចៈ ទុក្ខសមុទយសច្ចៈ (បានដល់តណ្ហា) និងមគ្គសច្ចៈ (បានដល់អរិយមគ្គមានអង្គ ៨) ជាធម៌មាននៅក្នុងលោក ជាធម៌តាំងនៅក្នុងសភាពជាទុក្ខ បើមិនទុក្ខដោយសភាវៈ ក៏ជាទុក្ខដោយលក្ខណៈដែរ ចំណែកនិរោធសច្ចៈ គឺព្រះនិព្វាន ជាធម៌ផុតចាកលោក ជាធម៌មិនតាំងនៅក្នុងសភាពជាទុក្ខ កុំពោលថ្វីដល់ទៅទុក្ខដោយសភាវៈ សូម្បីតែទុក្ខដោយលក្ខណៈ ក៏មិនមានដែរ ព្រោះជា

អសង្ខតធម៌ ជាធម៌ដែលមិនមានបច្ច័យ តាក់តែងឲ្យកើត ។

បើយើងសង្កេតមើល សត្វលោក នៅក្នុងសកលធាតុនេះ វៀរលែងតែព្រះអរិយៈទាំងឡាយចេញហើយ គឺកំពុងតែរស់នៅក្នុងសច្ចៈពីរប្រការខាងដើម គឺ ទុក្ខសច្ចៈ និងទុក្ខសមុទយសច្ចៈ ។

## លោកាមិសសុខ

សេចក្តីសុខសោមនស្ស ដែលជនក្នុង



លោកប៉ងប្រាថ្នា សូម្បីសុខជារបស់មនុស្សក្តី សុខជារបស់ទិព្វក្តី សុទ្ធតែជារបស់ក្លែងបន្លំ សឹងពោរពេញទៅដោយ ការបោកប្រាស់ ប្រកបដោយចិត្តដែលមានលោភៈ ឬតណ្ហាជាឫសគល់ ។

សេចក្តីសុខ ក្នុងកាមារម្មណ៍ទាំងអស់ បើដកយកតែតណ្ហា សេចក្តីប្រាថ្នាចេញហើយ គឺនឹងទៅជាវត្ថុមិនមានគុណតម្លៃ ដោយស្វ័យប្រវត្តិ ហើយប្តូរជំនួសដោយការនឿយណាយមិនខានឡើយ ព្រោះក្នុងលោកនេះ មិនមាន

សេចក្តីសុខណា សូម្បីមួយដែលចាត់ជា
សុខសច្ចៈនោះឡើយ ត្រឹមតែជាសម្មតិសុខ
ប៉ុណ្ណោះ ទើបបានជាសេចក្តីសុខនៅក្នុងលោក
ទាំងអស់ មានឈ្មោះថា ជាលោកាមិសៈ
ជាការបោកប្រាស់របស់លោកនេះប៉ុណ្ណោះ ។

សុខដែលជាលោកធម៌ ដែលព្រះ
សាស្តាទ្រង់ត្រាស់ ជាស់តឿនសត្វលោកនោះ
គឺសំដៅដល់ សេចក្តីសុខក្លែងក្លាយក្នុងលោក
នេះឯង ដើម្បីឲ្យសត្វលោកមានស្មារតីឡើង
ឲ្យកំណត់ដឹងថា ជារបស់មិនទៀង ជាទុក្ខ និង



មានការអស់ទៅ សូន្យទៅជាធម្មតា ដើម្បី
ការពារនូវសេចក្តីសោកស្តាយ នៅពេលដែល
សេចក្តីសុខនោះវិនាសទៅ និងដើម្បីកាត់នូវ
សេចក្តីអាល័យទាំងស្រុង អំពីសេចក្តីសុខ
ក្លែងបន្លំទាំងអស់នោះ ។

## ហេតុអ្វីក៏ព្រះពុទ្ធតែងសម្តែងអំពីទុក្ខ ?

តាមធម្មតា មនុស្សដែលអាចឈាន
ចូលទៅរកភាពជោគជ័យក្នុងជីវិត គឺទាល់តែ
ស្គាល់នូវសេចក្តីទុក្ខលំបាកក្នុងជីវិត ឲ្យបាន

ច្បាស់លាស់ ទើបជាអ្នកមានស្មារតី តស៊ូ ព្យាយាម បំពេញការងារដោយមិនរាថយ រហូតបានទទួល នូវសេចក្ដីសម្រេចក្នុងជីវិត ព្រោះមានសេចក្ដីទុក្ខលំបាកនោះឯង ជាគ្រឿងដាស់តឿនគំនិត ឬថាជាបទពិសោធន៍ ដើម្បីឲ្យមានសេចក្ដីព្យាយាមកាន់តែខ្លាំងឡើង ។

មាតាបិតា តែងដាស់តឿនក្រើនរំលឹក កូនប្រុសស្រី ឲ្យប្រយ័ត្នខ្លួននៅពេលដែលកូនធ្វើដំណើរទៅទីណាៗ ក្រែងកូនមានគ្រោះថ្នាក់ ហើយពាក្យគ្រោះថ្នាក់ ដែលមាតាបិតាប្រាប់



ដល់កូនសម្លាញ់របស់គាត់នោះ មិនមែនចង់ឲ្យកូនជួបនូវគ្រោះថ្នាក់ឡើយ គឺចង់ឲ្យកូនបានរួចអំពីគ្រោះថ្នាក់គ្រប់ប្រការ ។

អង្គការសុខភាព ដែលគេខំផ្សព្វផ្សាយអំពីគ្រោះថ្នាក់ ដែលកើតអំពីជំងឺអេដស៍ ដោយប្រើថវិកាជាច្រើន មិនមែនគេចង់ឲ្យមនុស្សគ្រប់គ្នាឆ្លងជំងឺអេដស៍នោះទេ គឺគេចង់ឲ្យមនុស្សគ្រប់គ្នាការពារខ្លួន ដើម្បីកុំឲ្យធ្លាក់ខ្លួនឆ្លងមេរោគអេដស៍នោះឯង ។

អង្គការស៊ីម៉ាក់ (CMAC) ដែលធ្វើ

ការផ្សារដោះមីន នៅកន្លែងណាដែលដោះមិនទាន់អស់ គេក៏ដាក់សញ្ញាក្បាលខ្មោច ប្រាប់ថា "ប្រយ័ត្នគ្រោះថ្នាក់ ដោយសារគ្រាប់មីន" ការដាក់សញ្ញាគ្រោះថ្នាក់ដូច្នេះ មិនមែនគេចង់ឲ្យមនុស្សជួបនូវសេចក្ដីគ្រោះថ្នាក់នោះទេ គឺគេហាមមនុស្សគ្រប់គ្នាកុំឲ្យគ្រោះថ្នាក់ ។

យ៉ាងណាមិញ ការដែលព្រះសាស្ដាតែងតែទ្រង់ត្រាស់សម្ដែងជារឿយៗ អំពីសេចក្ដីទុក្ខ គឺដើម្បីរំលឹកដាស់តឿនសត្វលោក ឲ្យស្គាល់នូវសេចក្ដីទុក្ខឲ្យបានច្បាស់



ហើយឲ្យប្រឹងប្រែងព្យាយាម គេចចេញអំពីសេចក្ដីទុក្ខទាំងអស់នោះឯង ដែលជាការសម្ដែងឡើងដោយមាន មហាករុណាទិគុណដ៏ធំធេង មិនមែនព្រះអង្គចង់ឲ្យសត្វលោកទទួលរងទុក្ខនោះឡើយ ។ ដូច្នេះ គួរតែយើងទាំងអស់គ្នាស្វែងយល់ឲ្យបានច្បាស់ អំពីបញ្ហានេះ ។

## ត្រូវត្រៀមខ្លួនទុកជាមុន

ជាធម្មតា អ្នកឡើងទៅប្រកួតល្បែង

កីឡា ត្រូវតែត្រៀមខ្លួនរង់ចាំទទួលលទ្ធផលទាំងពីរ គឺចាញ់និងឈ្នះ យ៉ាងណាមិញ នៅក្នុងការប្រណាំងក្នុងឆាកជីវិតនេះ ក៏ត្រូវតែត្រៀមខ្លួនរង់ចាំទទួលលទ្ធផលពីរយ៉ាងដែរ គឺសុខ និងទុក្ខ ព្រោះរបស់ទាំងពីរនេះគង់តែមកដល់ជីវិតមិនខាន គ្រាន់តែមិនប្រាកដថា តើរបស់ណាមួយមកដល់មុនតែប៉ុណ្ណោះ ។

ការត្រៀមខ្លួន រង់ចាំទទួលសេចក្ដីសុខ គឺជាពាក្យដែលងាយស្ដាប់ ហើយជាទីប្រាថ្នានៃជនច្រើនគ្នា ។



ចំណែកពាក្យថា ត្រូវត្រៀមខ្លួនរង់ចាំទទួលសេចក្ដីទុក្ខ គឺសត្វលោកមិនសូវគិតដល់ ហើយអាចគិតថា ជាពាក្យចង្រៃទៀតផង នេះឯងគឺជាចំណុចខ្សោយរបស់សត្វលោក ។

ការត្រៀមខ្លួន រង់ចាំទទួលសេចក្ដីទុក្ខនេះ មិនមែនបានន័យថា ឲ្យយើងគ្រប់គ្នាកើតទុក្ខជាមុននោះឡើយ គឺជាពាក្យដាស់តឿនឲ្យយើងមានសេចក្ដីក្លាហាន ហ៊ានតទល់គ្រប់សេចក្ដីទុក្ខក្នុងជីវិត ហើយសេចក្ដីទុក្ខដែលគ្រប់គ្នាមិនអាចគេចផុត គឺ ចាស់ ឈឺ និងស្លាប់ ។

កាលណាយើងធ្លាក់ខ្លួនឈឺ ចូរកុំមាន

សេចក្ដីកង្វល់ យើងត្រូវតែមានសេចក្ដីក្លាហាន
ទ្រាំទ្រនឹងជំងឺនោះ ឲ្យបានយ៉ាងដាច់ខាត យើង
ត្រូវលួងលោម បបោសអង្អែលចិត្តរបស់
យើងថា យើងបានឆ្លងកាត់សេចក្ដីទុក្ខជាច្រើន
កន្លងមកហើយ ទាំងក្នុងជាតិនេះ ទាំងក្នុង
អតីតជាតិ សូម្បីជំងឺធ្ងន់ជាងនេះ យើង
ក៏អាចទ្រាំបានដែរ ហើយគួរបានរលឹកថា
សូម្បីព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងអគ្គសាវក
ក៏ត្រូវទ្រាំរងទុក្ខ ដែលបណ្ដាលមកអំពី រោគា
ព្យាធិ និងសេចក្ដីគ្រោះថ្នាក់ផ្សេងៗ ដែរ



ហើយនិងត្រូវចេះដឹង អំពីសភាពធម្មតានៃ
ធម្មជាតិនៅជុំវិញជីវិតរបស់យើងផង ព្រោះ
អ្វីៗ សុទ្ធតែប្រព្រឹត្តទៅធម្មតាតាមទំនៀម
របស់វា ដូចជាផ្លែឈើដែលធ្លាក់ចាកមែក
មានទាំង ខ្ចី ចាស់ និងទុំ យ៉ាងណាមិញ ឈឺ
និងស្លាប់ រមែងកើតមានដល់មនុស្សយើងទាំង
វ័យក្មេង វ័យកណ្ដាល និងវ័យចាស់ ជារឿង
ធម្មតា ធ្វើដូច្នេះ យើងនឹងមិនកើតទុក្ខជា
មុនឡើយ តែជាអ្នកបានត្រៀមខ្លួនទុកជាមុន ។

☞ សុខទុក្ខជាគូគ្នា

គ្រប់អង្គាចៀសមិនបាន

សព្វទីកពភូមិឋាន

សត្វគ្រប់ប្រាណជួបដូចគ្នា ។

☞ បើបានជួបក្ដីសុខ

ត្រូវចាំទុកគ្រប់វេលា

សុខនោះគង់ប្រែជា

ឲ្យទុក្ខាជាក់មិនខាន ។



# គោតមប្រវត្តិ

☞ ខ្ញុំសូមថ្វាយវន្ទា

ព្រះសាស្ដាដ៏មានបុណ្យ

និងសូមគោរពគុណ

គ្រាព្រះអង្គចុះចាកឋាន ។

☞ មកចាប់ផ្ទៃមាតា

ស្រីស្រីង្គារស្រស់កល្យាណ

កាលនោះមហាជនបាន

សុខក្សេមក្សាន្តព្រោះបារមី ។

☞ ក្នុងថ្ងៃព្រហស្បតិ៍អា-

សាធមាសាពេញបូណ៌មី

រកាជាឆ្នាំថ្មី

សុខសិរីដល់ជនា ។

☞ កាលបាន១០ខែហើយ

ព្រះគុណអើយកើតអស្ចារ្យ

នៅនាដងព្រឹក្សា

ឈ្មោះហៅថាព្រៃសាលវ័ន ។

☞ កក្រើកផែនពសុធា

មានទេវតារាប់រយពាន់



ស្ថិតនៅក្នុងតំបន់

នៃឧទ្យានលុម្ពិនី ។

☞ ឆ្នាំចពិសាខនា

ថ្ងៃសុខជាពេញបូណ៌មី

ថ្ងៃនោះព្រះជិនស្រី

ទ្រង់ប្រសូតឥតមានព្រួយ ។

☞ កាលសិទ្ធត្ថក្សត្រា

មានវស្សាដប់ប្រាំមួយ

បិតាបានលើកសួយ

អភិសេកទឹងស្រីង្គារ ។

☞ នារីស្រស់កល្យាណ

អ្នកផងបានស្គាល់គ្រប់គ្នា

ថាឈ្មោះនាងពិម្ពា

ស្រស់សោភាលើសលែងក្រៃ ។

☞ កាលនោះក្នុងឆ្នាំឆ្លូវ

ត្រូវថ្ងៃសៅរ៍មានសិរី

អាសាឍពេញបូណ៌មី

ក្សត្រាថ្លៃបានសុខា ។

☞ ស្ដេចមានព្រះរាជបុត្រ

បរិសុទ្ធភ័ក្ត្រស្រស់ថ្លា



គួរឲ្យព្រះរាជា

ស្ដេចជំពាក់ចិត្តពេកក្រៃ ។

☞ តែទ្រង់បានកាត់ផ្ដាច់

ទ្រង់សម្រេចព្រះហឫទ័យ

ថាត្រូវកាត់អាល័យ

ពីបុត្រថ្លៃមួយគ្រាណា ។

☞ បើបិតាបានត្រាស់

វិលរហ័សរកបុត្រា

មកប្រោសស្ងួនពុំងា

ចាកសង្សារណាបុត្រថ្លៃ ។

☞ កាលនោះថ្ងៃព្រហស្បតិ៍

ក្នុងឆ្នាំឋោះមានសិរី

អាសាឍពេញបូណ៌មី

ក្សត្រាថ្ងៃចេញបព្វជ្ជា ។

☞ កាលបានបព្វជ្ជាហើយ

មិនព្រងើយខំឧស្សាហ៍

ធ្វើទុក្រកិរិយា

គ្មាននរណាធ្វើដូចអី ។

☞ បានត្រាស់ឆ្នាំរកា

ពិសាខាពុធបុណ្ណមី



ជាថ្ងៃព្រះជិនស្រី

មានសិរីឈ្មោះក្រុងមារ ។

☞ ត្រាស់ដឹងបានពីរខែ

ទ្រង់គ្មាន់គ្នេរប្រោសទេសនា

ប្រោសបញ្ចវគ្គិយា

នាកណ្ដាលដងព្រឹក្សព្រៃ ។

☞ គឺក្នុងឆ្នាំរកា

អាសាឍមាសាបុណ្ណមី

ថ្ងៃសៅរ៍ព្រះជិនស្រី

ផ្ដើមពោលស្ដីធម៌ទេសនា ។

☞ ក៏ជាថ្ងៃកំណើត
សង្ឃបានកើតក្នុងលោកា
សាវ័កព្រះសាស្តា
មានរហូតដល់សព្វថ្ងៃ ។

☞ នាថ្ងៃមួយនោះណា
គួរសោកាណាស់ម្ចាស់ថ្លៃ
គឺថ្ងៃព្រះជិនស្រី
កាត់ព្រះទ័យដាក់សង្ខារ ។

☞ គឺក្នុងថ្ងៃអាទិត្យ
ឆ្នាំម្សាញ់ពិតមាឃមាសា



នៅចំពោះមុខមារ
នាបាវាលចេតិយ ។

☞ បីខែកន្លងទៅ
មិនឈប់នៅយឺនយូរអើ
ដល់ថ្ងៃព្រះជិនស្រី
ទ្រង់និព្វានចាកលោកា ។

☞ គឺក្នុងឆ្នាំនោះឯង
មានការផ្សេងតែមាសា
គឺខែពិសាខនា
ថ្ងៃអង្គារពេញបូណ៌មី ។

☞ ដោយអំណាចអានុភាព

ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍

ទឹកគុណព្រះមុនី

សូត្រប្រវត្តិព្រះសាស្តា ។

☞ សូមឲ្យសម្រេចបុណ្យ

ដែលជាគុណល្អថ្លៃថ្លា

អន្ទោលក្នុងសង្សារ

សូមប្រាថ្នាជួបបណ្ឌិត ។

☞ សូមជួបព្រះសិអារ្យ

ជាសាស្តាដ៏ពិសិដ្ឋ



សូមបាក់ដ្ឋុះធម៌ពិត

សមដួចចិត្តប្រាថ្នាហោង ។



# ឈ្មោះមាតាបិតា ៤ យ៉ាង

មាតាបិតា ព្រះពុទ្ធទេសនា
ថាមានឈ្មោះបួន ខ្ញុំនឹងរៀបរាប់
តាមបែបកាព្យជូន ឲ្យគ្រប់ចំនួន
ទាំងបួនប្រការ ។

ទីមួយនោះ ព្រះពុទ្ធដាក់ឈ្មោះ
ថាព្រះព្រហ្ម ព្រោះលោកសម្បូណ៌



ដោយព្រហ្មវិហារ លើកូនគ្រប់គ្នា
មិនមែនប្យិចប្យៀម ។

ទីពីរឈ្មោះថា បុព្វ ទេវា
ទេវតាខាងដើម អ្នកផ្ដើមរក្សា
បុត្រគ្រប់ដង្ហើម ព្រោះព្រំផ្សះផ្សើម
ដង្ហើមកូនរស់ ។

ទីបីនោះណា ទ្រង់ត្រាស់ទេសនា

បាលីពីរោះ　　　គឺបុញ្ញចារ្យ
គ្រូដើមបង្អស់　　　បង្រៀនដោយស្មោះ
　　ឥតលាក់លៀមអ្វី ។

វីទីប្អូននោះ　　　ព្រះអង្គដាក់ឈ្មោះ
ជាអាហុនេយ្យ　　　បុគ្គលប្រសើរ
គួរកូនប្រុសស្រី　　　ក្រាបថ្វាយវន្ទីយ៍
　　គោរពបូជា ។





# ព្រៃគោសិង្គសាលវ័ន
# រុងរឿងដោយសារតិភ្ញណា ?

ពេលមួយក្នុងព្រៃគោសិង្គៈ
　　មានព្រះកស្សបៈព្រះអនុរុទ្ធ
ព្រះមោគ្គល្លានព្រះសារីបុត្ត
　　ជាសាវកពុទ្ធឆ្នាតប្រពៃ ។
ទាំងព្រះអានន្ទពុទ្ធុបដ្ឋាក
　　ថែមព្រះរេវតៈព្រះនាមល្បី
កំពូលថេរៈមានគុណក្រៃ
　　នាំគ្នាឃ្មាតខ្មីថ្វាយបង្គំ ។
ព្រះមានព្រះភាគក្រាបទូលថា
　　"ពួកខ្ញុំព្រះករុណាបានប្រជុំ

ព្យាករបដិភាណតាមសមរម្យ
វៀងខ្ទនដោយពុំហ៊ានមុសា ។
ខ្ញុំសារីបុត្តសួរអានន្ទ
ថាព្រៃសាលវ័នគួរជ្រះថ្លា
ដើមឈើទាំងឡាយក៏មានផ្កា
ចម្រុះល្អស្រស់រីកស្គុសស្គាយ។
ក្រអូបឈ្ងុយឈ្ងប់សព្វកន្លែង
គួរនាជួចក្លិនទិព្វផ្សព្វផ្សាយ
រាត្រីសោតក៏គួររីករាយ
ពពកឃ្លាតឆ្ងាយមេឃស្រឡះ។
គ្មានទឹកសន្សើមគ្មានផ្សែងអ័ព្ទ
គ្មានរាហូចាប់ដីហុយប៉ះ
អានន្ទចូរអ្នកឆ្លើយប្រកាស



ព្រៃគោរុងរឿងដោយភិក្ខុណា?។
ព្រះអានន្ទតបក្នុងសាសនានេះ
ភិក្ខុចាំបេះពុទ្ធវចនា
ទ្រទ្រង់សន្សំព្រះដីកា
ធម៌ទាំងឡាយណាមានលំអ ។
បទដើមកណ្តាលនិងបទចុង
គ្រប់ព្យញ្ជនៈក្នុងវេយ្យាករណ៍
ប្រកាសនូវព្រហ្មចរិយៈដ៏
បរិសុទ្ធ-បរិបូណ៌ទាំងអស់ ។
ធម៌ទាំងឡាយណាមានភាពដូច្នេះ
ភិក្ខុនោះបេះគ្មានចន្លោះ
ជំនាញរត់មាត់ស្ទាត់ឥតខ្ចោះ
ស្ម័គ្រស្មោះពិចារណាដោយចិត្ត។

ភិក្ខុនោះតែងសម្តែងធម៌
ដល់បរិស័ទល្អបួនពួកពិត
ដោយបទនិងព្យញ្ជនៈលម្អិត
ជាបរិមណ្ឌលជាប់តគ្នា។
ដើម្បីជួយដាស់គាស់រំលើង
នូវអនុស័យគ្រប់វេលា
ព្រៃគោរុងរឿងបានដោយសារ
ភិក្ខុនេះណាសារីបុត្ត។
រូបខ្ញុំព្រះអង្គសួរបន្ត
រេវតៈឆ្លើយតគ្មានតក់ស្លុត
ម្នាលអាវុសោសារីបុត្ត
ភិក្ខុនៅក្នុងពុទ្ធសាសនា។
ត្រេកអររីករាយពួនសម្ងំ



រឿយៗអប់រំនូវបញ្ញា
ស្ងប់ស្ងាត់ចិត្តដោយវិបស្សនា
ចម្រើនសុញ្ញាគារធម៌។
ព្យាយាមប្រព្រឹត្តក្នុងសន្តាន
មិនប្រាសចាកឈានថ្ងៃបវរ
ព្រៃគោសាលវ័នមានលំអ
រុងរឿងដោយសារភិក្ខុនោះ។
រូបខ្ញុំព្រះអង្គសួរអនុរុទ្ធ
ប្រាជ្ញាស្រួចមុតឆ្លើយពីរោះ
ក្នុងពុទ្ធសាសនាដ៏ខ្ពង់ខ្ពស់
ភិក្ខុមើលឃើញនូវលោកធាតុ។
មួយពាន់ដោយភ្នែកបរិសុទ្ធថ្លា
ដូចទិព្វចក្ខុប្រសើរស្អាត

កន្ទងហួសក្អែកមនុស្សគ្រប់ជាតិ
ប្រៀបដូចបុរសនៅខាងលើ។
ក្រឡេកឃើញមណ្ឌលនៃខ្នងកង់
មួយពាន់ច្បាស់ត្រង់គ្រប់អន្ទើ
មើលពីប្រាសាទដ៏ប្រសើរ
ព្រៃគោរុងរឿងបានដោយសារ។
ភិក្ខុនោះឯងជាលំអ
ខ្ញុំព្រះអង្គបន្តសាកប្ហា
សួរមហាកស្សបៈដ៏ថ្លៃថ្លា
លោកក៏ឆ្លើយថាសាសនាព្រះ។
ពុទ្ធអង្គមានសង្ឃអ្នកនៅព្រៃ
សរសើរគុណនៃអ្នកបានលះ
មិនជាប់ជំពាក់ញាតិទ្រព្យផ្ទះ



ចិត្តផុតស្រឡះអស់សៅហ្មង។
ភិក្ខុនោះឯងតែងប្រព្រឹត្ត
បិណ្ឌបាតឆ្ងាយជិតទាំងទ្រទ្រង់
សំពត់បង្សុកូលខ្លួនឯងផង
សរសើរកន្ទងលោកផងគ្នា។
ភិក្ខុទ្រទ្រង់ត្រឹមតែបី
នូវចីវរត្រៃដែលត្រូវការ
ជាអ្នកមិនមានក្ដីប្រាថ្នា
សន្ដោសខ្លាំងក្លាដោយសុទ្ធចិត្ត។
ជាអ្នកស្ងប់ស្ងាត់មិនប្រឡូក
ប្រឡំផ្សំបូកនឹងញាតិមិត្រ
ប្រុងប្រៀបព្យាយាមខ្លួនឯងពិត
សំអាតផ្លូវចិត្តពុំមានខ្ជិល។

ជាអ្នកបរិបូណ៌ដោយបញ្ញា

ច្រើនទាំងសមាធិនិងសីល

បរិបូណ៌វិមុត្តិឥតវល់វិល

រួចផុតមន្ទិលចូលដល់ថ្នាក់ៗ

ជាអ្នកបរិបូណ៌បរិសុទ្ធ

ព្រមដោយវិមុត្តិញាណទស្សនៈ

បានសរសើរគុណដោយស្មោះស្ម័គ្រ

លោកអ្នកទ្រទ្រង់គុណដូចគ្នាៗ

ព្រៃគោរុងរឿងភ្លឺត្រចះ

ដូចមេឃស្រឡះមានចន្ទ្រា

ក៏ដោយភិក្ខុរូបនេះណា៎

សារីបុត្តមេត្តាជ្រាបសេចក្ដីៗ

តមកដល់វេនមហាមោគ្គល្លាន



ព្យាករតបដិភាណដោយប្រពៃ

លោកមានអាយុបាននិយាយ

ថាម្នាលសារីបុត្តថ្លៃថ្លាៗ

ភិក្ខុពីររូបឈ្លាសមុតមាំ

សំដែងអភិធម្មកថា

សាកសួរហើយដោះស្រាយប្រស្នា

ដល់គ្នានិងគ្នាឥតសៅហ្មងៗ

កថារបស់ភិក្ខុនោះ

ប្រព្រឹត្តទៅស្មោះដោយធម៌ផង

មិនបានរុករានគ្នាលោកផង

សុខស្ងប់កន្ទងធម្មសប្បាយៗ

ម្នាលអាវុសោសារីបុត្ត

ព្រៃគោល្អផុតទីងបរិយាយ

រុងរឿងដោយភិក្ខុទាំងឡាយ
សាកសួរដោះស្រាយប្រស្នាធម៌។
រួចព្រះមោគ្គល្លានក្រាបបង្គំ
ទូលម្ចាស់ឧត្តម[១]ជាបន្ត
ថា "យើងរាល់គ្នាបានព្យាករ
បដិភាណសមល្អដល់ខ្លួនហើយ។
ឥឡូវសូមសួរសារីបុត្ត
ចុងគេបំផុតមេត្តាឆ្លើយ
ព្រះសារីបុត្តមិនកន្តើយ
ឆ្លើយប្រាប់ពួកយើងយ៉ាងនេះថា។
ម្នាលអាវុសោមោគ្គល្លាន
ភិក្ខុដែលមានក្នុងសាសនា
ព្រះមានព្រះភាគដ៏ថ្លៃថ្លា

(១) គឺព្រះសម្មាសម្ពុទ្ធ



បញ្ញាផ្តាច់ការទៅលើចិត្ត។
ឲ្យធ្វើតែក្នុងអំណាចខ្លួន
ប្តេជ្ញាមាំមួនមិនប្រព្រឹត្ត
មិនលុះទៅតាមអំណាចចិត្ត
រួចផុតចាកពិតកាមាសវៈ។
បើភិក្ខុនោះប្រាថ្នាដើម្បី
នៅអស់សម័យបុព្វណ្ហៈ
ឬនៅអស់មជ្ឈន្តិកៈ
អស់សាយណ្ហៈក៏នៅបាន។
សុខដោយវិហារសមាបត្តិ
ប្រៀបដូចមហាមាត្យនិងក្សត្រក្សាន្ត
ទ្រទ្រង់សំពត់គូប៉ុន្មាន
ក៏អាចនៅបានគ្រប់វេលា។

ព្រៃគោសិង្គសាលវ័ន
រុងរឿងសោភ័ណក៏ដោយសារ
ភិក្ខុដែលបានតាំងប្ដេជ្ញា
ប្រើបញ្ញាការទៅលើចិត្ត"។
ពេលនោះសម្តេចព្រះទ្រង់ញាណ
សរសើរបដិភាណខ្ពស់ប្រណីត
ដែលគ្រប់សាវ័កទូលលំអិត
ព្យាករត្រូវពិតគួរជ្រះថ្លា។
រួចហើយព្រះសារីបុត្តផ្គុំ
ហត្ថក្រាបបង្គំព្រះសាស្តា
"សូមព្រះរាជទានប្រោសមេត្តា
តើលោកអង្គណានិយាយត្រូវ"។
ស្តេចទ្រង់ត្រាស់ថា"សារីបុត្ត



ទាំងអស់គ្នាសុទ្ធតែត្រឹមត្រូវ
អាចញ៉ាំងព្រៃគោរុងរឿងទៅ
តែអ្នកទាំងឡាយចូរចាំស្តាប់!។
ភិក្ខុនៅក្នុងសាសនានេះ
ឆាន់ហើយត្រិះរិះស្រួតប្រញាប់
អង្គុយពែនភ្នែនតាមទម្លាប់
ឆាប់ពត់កាយត្រង់ផ្ចង់ស្មារតី។
ឲ្យត្រង់ទៅមុខដោយគិតថា
បើចិត្តអាត្មានៅអាល័យ
នៅប្រកាន់ជាប់ទ្រព្យលោកិយ
មិនរួចពីភ័យគឺអាសវៈ។
ទេនោះអញនឹងមិនទម្លាយ
ភ្នែនចេញឆាយៗនាំឲ្យអាក់

ទីព្រៃសាលវ័នគោសិង្គ:

រុងរឿងដោយសារភិក្ខុនោះ”ៗ

គ្រប់អង្គស្តាប់ចប់ពុទ្ធភាសិត

ត្រេកអរពេញចិត្តដោយចំពោះ

ព្រះសូរសៀងថ្លៃសែនពីរោះ

សម្តេចទ្រង់យសព្រោសប្រទានៗ

ដោយឧបាសិកា **ខិម លក្ខណា**



**អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ**

ធម្មាចារ្យ គម្ពីរប្បញ្ញោ វួច សុធី

ឧទ្ទេសាចារ្យ សីលសំវរោ ស៊ូ សាមុត

សាមណេរ បញ្ញាបរមោ ឈាត ប៊ុនធាត

## សៀវភៅធម៌

## ដែលខ្ញុំព្រះករុណាអាត្មាភាពបានរៀបរៀង

១-រលកលោកធម៌

២-ព្រះធម្មបទ៣០គាថា

៣-ប្រយោជន៍ ៣ ប្រការ

៤-ជីវិត (Life)

៥-បងប្អូនជួបគ្នាមួយគ្រាមានន័យ

៦-ឧបមាគុណព្រះរតនត្រៃម្ភៃពីរប្រការ (កំណាព្យ)

៧-អភិធម្មត្ថសង្គហៈ បរិច្ឆេទទី៤

៨-អភិធម្មសង្គណី តិកមាតិកាសង្ខេប

៩-ជីវិតពិតជាត្រូវការធម៌

១០-តើនរកមានដែរឬទេ ?

**ព្រះធម៌គឺជាផែនទីនៃជីវិត**



## ប៉ុស្តិ៍វិទ្យុដែលខ្ញុំព្រះករុណាអាត្មាភាព

## កំពុងសម្តែងព្រះធម៌ផ្សព្វផ្សាយនាពេលបច្ចុប្បន្ន

☞ ខេត្តពោធិ៍សាត់ វិទ្យុ FM 100.50 MHz

-ចាប់ពីម៉ោង ៦.៣០ pm ⇨ ៧.០០ pm រៀងរាល់ល្ងាចៗ

☞ ខេត្តពោធិ៍សាត់ វិទ្យុ FM 98.50 MHz

-ចាប់ពីម៉ោង ៧.០០ pm ⇨ ៨.០០ pm រាល់ល្ងាចថ្ងៃសីលៗ

☞ ខេត្តកំពង់ធំ វិទ្យុ FM 107.30 MHz

-ចាប់ពីម៉ោង ៦.០០ am ⇨ ៦.៣០ am រៀងរាល់ព្រឹកៗ

☞ ក្រុងកំពង់សោម វិទ្យុ FM 92.00 MHz

-ចាប់ពីម៉ោង ៦.៣០ pm ⇨ ៧..០០ pm រៀងរាល់ល្ងាចៗ

**សុខា សទ្ធម្មទេសនា**

ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ



## បុគ្គលឯក

“បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ តើបុគ្គលឯកនោះគឺនរណា ?

**គឺព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ**”








កន្លែងសម្តែងអនត្តលក្ខណសូត្រ



កន្លែងព្រះអង្គបរិនិព្វាន



ប្រាសាទដំបូលមាស
តម្កល់ព្រះចង្កូមកែវនៃព្រះសម្មាសម្ពុទ្ធ



ចក្កឃោសិតារាមនៅកោសម្ពី (ឥណ្ឌា)



ភ្នំមហិន្ទបព៌ត

បោះពុម្ពចែកជាធម្មទាន

ចំនួន ១០.០០០ ក្បាល

រោងពុម្ព អ៊ឹម សាវ័ន្ត

# ពន្លត់ទោសៈដោយខន្តី



ព្រះបរមពោធិព្រឹក្ស ប្រតិស្ឋាននៅ
មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន

បើដឹងគេខឹងកុំប្រឹងតបត តាំងចិត្តឱ្យល្អធ្វើគថ្លង់ខ្វាក់
ខន្តីអត់ធ្មត់ពន្លត់ទោសៈ ចិត្តមិនប្រឡាក់បានសុខបានបុណ្យ

*ដោយឧបាសិកា ឱម លក្ខណា*